ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

លេខ: ០៥៩ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍



អាសយដ្ឋាន: ជិឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

-បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

-យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពង់ឆ្នាំង

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចនេះ។

**ប្រការ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពង់ឆ្នាំង និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មស្រុកបរិបូណ៌ត្រូវរៀបចំផែនការសម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើនេះឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មស្រុកបរិបូណ៌ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌មុនពេលកំណត់អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំងនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពង់ឆ្នាំង និងអភិបាលនៃគណៈអភិបាលស្រុកបរិបូណ៌និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មស្រុកបរិបូណ៌ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ពុធ ១២កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ០៥៥ សសរ ចុះថ្ងៃពុធ ១២ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ត្រូវនឹងថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២០
ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង

# ប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌

## ចក្ខុវិស័យឆ្នាំ ២០៣០

# មាតិកា

ទំព័រ


១-សេចក្តីផ្តើម ------------------------------------------------ ១

២-ក្របខណ្ឌសេដ្ឋកិច្ច សង្គម និងចក្ខុវិស័យស្រុកបរិបូណ៌ ----------- ២

២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម ------------------------------- ២

២.២-ចក្ខុវិស័យ ---------------------------------------------- ៣

៣-គោលបំណងនិងគោលដៅនៃប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ ------ ៣

៣.១-គោលបំណង --------------------------------------------- ៣

៣.២-គោលដៅ ---------------------------------------------- ៣

៤-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សស្រុកបរិបូណ៌ប្រកបដោយប្រសិទ្ធភាពនិងចីរភាព ------ ៤

៤.១-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សតំបន់ទីប្រជុំជននិងតំបន់ជនបទ ------ ៤

៤.១.១-ការអភិវឌ្ឍនគរូបនីយកម្ម ------------------------------ ៤

៤.១.២-ការកំណត់ទិសដៅនគរូបនីយកម្ម ------------------------ ៥

៤.១.៣-ការរៀបចំនិងការអភិវឌ្ឍតំបន់ជនបទ ---------------------- ៥

៤.២-យុទ្ធសាស្ត្រគ្រប់គ្រងនិងប្រើប្រាស់ដី ------------------------ ៥

៤.២.១-ប្រភេទដីកម្រិតការសាងសង់ ----------------------------- ៦

៤.២.២-ប្រភេទដីអាចសាងសង់បាន ------------------------------ ៧

៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ------------------------ ៩

៤.៣.១-ផ្លូវគោក ------------------------------------------- ៩

៤.៣.២-ផ្លូវទឹក ------------------------------------------- ១០

៤.៣.៣-ទឹកស្អាតនិងធនធានទឹក ------------------------------ ១០

៤.៣.៤-ថាមពលអគ្គិសនី ទូរគមនាគមន៍ និងព័ត៌មានវិទ្យា ---------- ១០

៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច ------------------------------ ១០

៤.៤.១-យុទ្ធសាស្ត្រអភិវឌ្ឍកសិកម្មនិងផ្សព្វផ្សាយផលិតផលក្នុងស្រុក ------ ១០

៤.៤.២-យុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ -------------------------- ១១

៤.៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍពាណិជ្ជកម្ម ------------------------- ១២

៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ចនិងវប្បធម៌ ---------------------- ១៣

៤.៦-យុទ្ធសាស្ត្រការពារបរិស្ថាននិងគ្រប់គ្រងសំណល់ ----------------- ១៤

៤.៦.១-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន ------ ១៤

៤.៦.២-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ --------------- ១៤

៤.៦.៣-យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង -------------------------- ១៥

៤.៦.៤-យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ -------------------------- ១៥

៤.៧-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ ---------- ១៦

៤.៨-យុទ្ធសាស្ត្រពង្រឹងអភិបាលកិច្ចល្អ គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន ---------- ១៧

៥-ផែនការសកម្មភាព ---------- ១៧

៥.១-ការរៀបចំបញ្ញត្តិនគរូបនីយកម្ម ---------- ១៧

៥.២-ការផ្សព្វផ្សាយ ---------- ១៧

៥.៣-ការអនុវត្តគម្រោងតាមវិស័យ ---------- ១៨

៥.៣.១-ការអភិវឌ្ឍស្រុកបរិបូណ៌ ---------- ១៨

៥.៣.២- ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន ---------- ១៨

៥.៣.៣-ការផ្គត់ផ្គង់ទឹកស្អាតនិងធនធានទឹក ---------- ១៩

៥.៣.៤-ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ និងព័ត៌មានវិទ្យា ---------- ១៩

៥.៣.៥-ការអភិវឌ្ឍកសិកម្មនិងផ្សព្វផ្សាយផលិតផលក្នុងស្រុក ---------- ១៩

៥.៣.៦- ការអភិវឌ្ឍទេសចរណ៍ ---------- ១៩

៥.៣.៧-ការការពារបរិស្ថាន ---------- ២០

៥.៣.៨- ការគ្រប់គ្រងសំណល់រឹង ---------- ២០

៥.៣.៩-ការគ្រប់គ្រងសំណល់រាវនិងប្រព័ន្ធបង្ហូរទឹកភ្លៀង ---------- ២០

៥.៣.១០-ការបង្ការទប់ស្កាត់គ្រោះមហន្តរាយ ---------- ២១

៥.៤-ការអនុវត្តគម្រោងរយៈពេលខ្លី មធ្យម និងវែង ---------- ២១

៥.៤.១-ការអនុវត្តគម្រោងរយៈពេលខ្លី ឬគម្រោងអាទិភាព ---------- ២១

៥.៤.២-ការអនុវត្តគម្រោងរយៈពេលមធ្យម ---------- ២១

៥.៤.៣-ការអនុវត្តគម្រោងរយៈពេលវែង ---------- ២២

៦-ធនធានហិរញ្ញវត្ថុ ---------- ២២

៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ---------- ២៣

៧.១-យន្តការ ---------- ២៣

៧.២-ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ---------- ២៣

៧.៣-ភារកិច្ច នីតិវិធី និងគោលការណ៍ ---------- ២៣

៨-សេចក្តីសន្និដ្ឋាន ---------- ២៤

អនុសាសន៍ ---------- ២៥

សន្ទានុក្រម ---------- ២៦

ឯកសារឧបសម្ព័ន្ធ ---------- ៣០


ꩩꩩꩩ

## ១-សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពដំណើរទៅមុខនៃការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែកនិងគ្រប់វិស័យក្នុងគោលដៅបង្កើននិងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាសំដៅធានាថាដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង រៀបចំ ប្រើប្រាស់ ការពារ និងបែងចែកដីធ្លីប្រកបដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព សមាហរណកម្ម និងចីរភាពដើម្បីរួមចំណែកធ្វើឱ្យសម្រេចនូវគោលដៅជាតិក្នុងការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាននិងធនធានធម្មជាតិ ការអភិវឌ្ឍស្របតាមបរិបថនៃសេដ្ឋកិច្ចទីផ្សារសេរី។ ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ដើម្បីធ្វើជាមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ក្នុងនោះមុំទី ៣ នៃចតុកោណទី ៤ គឺការពង្រឹងការគ្រប់គ្រងនគរូបនីយកម្មដោយកំណត់នូវគោលដៅជាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍទីក្រុង ទីប្រជុំជនឱ្យមានសោភ័ណភាពនិងមានបរិស្ថានល្អសម្រាប់ការរស់នៅដើម្បីលើកកម្ពស់សុខមាលភាពរបស់ប្រជាជននិងប្រសិទ្ធភាពសង្គម សេដ្ឋកិច្ច។

ស្ថិរភាពនិងវឌ្ឍនភាពនៃសង្គម សេដ្ឋកិច្ចនេះគឺជាកាលានុវត្តភាពជំរុញឱ្យមាននិន្នាការកើនឡើងយ៉ាងឆាប់រហ័សនៃកំណើនប្រជាជន ការប្រើប្រាស់ដីធ្លីនិងលំនៅឋាន ការរីករាលដាលនៃនគរូបនីយកម្ម និងការបង្កើតជាទីក្រុងតូចធំគ្រប់កម្រិតតាមលក្ខណៈពិសេសនៃតំបន់ភូមិសាស្ត្រនីមួយៗដែលទាមទារឱ្យមានការគិតគូរនិងរៀបចំកសាងឡើងជាបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជាប្រព័ន្ធគមនាគមន៍និងដឹកជញ្ជូន ថាមពលនិងអគ្គិសនី សុខភាព ទឹកស្អាត សំណល់រឹងនិងរាវ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការការពារប្រព័ន្ធអេកូឡូស៊ីនិងធនធានធម្មជាតិ។ល។

ខេត្តកំពង់ឆ្នាំងស្ថិតនៅភូមិភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ ៩១ គីឡូម៉ែត្រពីរាជធានីភ្នំពេញ មានផ្ទៃដីសរុប ៥ ៥២១ គីឡូម៉ែត្រក្រឡា និងមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ចាមនិងកំពង់ធំ ខាងលិចជាប់នឹងខេត្តពោធិ៍សាត់ ខាងត្បូងជាប់នឹងខេត្តកំពង់ស្ពឺនិងកណ្តាល និងខាងជើងជាប់នឹងខេត្តកំពង់ធំ និងបឹងទន្លេសាប។ រចនាសម្ព័ន្ធរដ្ឋបាលខេត្តនេះចែកចេញជាស្រុកចំនួន ៧ ក្រុងចំនួន ១ ឃុំ សង្កាត់ចំនួន ៧០ និងភូមិចំនួន ៥៦៩ ដែលមានប្រជាជនសរុប ៥៥០ ៨៩០ នាក់ ក្នុងនោះស្ត្រី ២៨៥ ៨១៨ នាក់ ស្មើនឹង ១៣០ ៩៧៨ គ្រួសារ។ សក្តានុពលសំខាន់ៗនៃខេត្តកំពង់ឆ្នាំងរួមមានប្រាសាទបុរាណចំនួន ១១ ភ្នំចំនួន ១១ ផ្សារធំៗ ចំនួន ១៥ សាលាអនុវិទ្យាល័យចំនួន ១៣ វិទ្យាល័យចំនួន ៧ មន្ទីរពេទ្យបង្អែកចំនួន ២ ព្រលានយន្តហោះចំនួន ១ និងស្ថានីយរថភ្លើងចំនួន ៥។

ស្រុកបរិបូណ៌ស្ថិតនៅភាគខាងជើងនៃខេត្តកំពង់ឆ្នាំងមានព្រំប្រទល់ជាប់នឹងខេត្តពោធិ៍សាត់និងបឹងទន្លេសាប ហើយក៏ជាស្រុកដែលមានសក្តានុពលយ៉ាងខ្លាំងលើវិស័យកសិកម្ម ផលិតកម្មស្រូវ និងផលនេសាទ។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងការអភិវឌ្ឍស្រុកបរិបូណ៌ប្រកបដោយចីរភាព គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពង់ឆ្នាំង និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មស្រុកបរិបូណ៌បានរៀបចំនូវប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ ចក្ខុវិស័យឆ្នាំ ២០៣០ ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងតម្រង់ទិសអភិវឌ្ឍដែនដីស្រុកបរិបូណ៌ទាំងមូលស្របតាមចក្ខុវិស័យនៃគោលនយោបាយជាតិស្តីពីការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជានិងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

ប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ ត្រូវបានកសាងឡើងដោយការសិក្សាច្បាស់លាស់លើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម បរិស្ថាន ប្រជាសាស្ត្រ ទេសចរណ៍ វប្បធម៌ និងការស្រង់មតិ ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានជាអាទិ៍ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ។ល។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌មានលក្ខណៈទូលំទូលាយគ្របដណ្តប់ទាំងឯកសារគតិយុត្ត និងបច្ចេកទេសសម្រាប់ធ្វើការសម្របសម្រួលជាមួយនឹងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ចសំដៅធ្វើការតម្រង់ទិសការអភិវឌ្ឍប្រកបដោយចីរភាព ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការក្នុងការប្រើប្រាស់ដីការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍគ្រប់កម្រិតក្នុងពេលបច្ចុប្បន្ននិងទៅអនាគតដោយធានាបាននូវការការពារធនធានដី ធនធានទឹកក្រោមដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិ ជាពិសេសការអភិរក្ស ធនធានធម្មជាតិតំបន់បឹងទន្លេសាប តំបន់ឆ្នុកទ្រូដែលរងការបំផ្លាញដោយសារសកម្មភាពអភិវឌ្ឍខុសបទដ្ឋានបច្ចេកទេស ឬដោយសារការប្រែប្រួលអាកាសធាតុដូចជាការបំភាយឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៃកម្តៅនៅក្នុងទីប្រជុំជន របបទឹកភ្លៀងមិនទៀងទាត់ ទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះជាដើម។

## ២-ក្របខណ្ឌសេដ្ឋកិច្ច សង្គម និងចក្ខុវិស័យស្រុកបរិបូណ៌

### ២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម

ដើម្បីកំណត់ចក្ខុវិស័យដល់ឆ្នាំ ២០៣០ ប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ត្រូវបានសិក្សានូវក្របខណ្ឌសេដ្ឋកិច្ច សង្គម ដោយផ្អែកតាមរបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនទូទៅនូវប្រជាសាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨ និងឆ្នាំ ២០១៩ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ តាមរយៈការសិក្សាខាងលើនេះ ស្រុកបរិបូណ៌មានផ្ទៃដី ៤២ ៣០៩ ហិកតា ចំនួនប្រជាជននៅឆ្នាំ ២០០៨ មានចំនួន ៥៤ ៧១៤ នាក់ ឆ្នាំ ២០១៨ មានចំនួន ៥៨ ៤១៧ នាក់ និងនៅឆ្នាំ ២០៣០ នឹងកើនឡើងដល់ ៦៣ ១៩៤ នាក់ ផ្អែកតាមការគណនាអត្រាកំណើនប្រចាំឆ្នាំ។ ជាមួយគ្នានេះ ការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ស្រុកបរិបូណ៌នៅឆ្នាំ ២០១៥ ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្មមាន ២៥ ៩២៦ នាក់ (៨៨%) ក្នុងវិស័យឧស្សាហកម្មធុនស្រាលនិងសិប្បកម្មមាន ១៧១ នាក់ (០,៦%) និងក្នុងវិស័យសេវាកម្មមាន ៣ ៣៦១ នាក់ (១១,៤%) ហើយរំពឹងថានៅឆ្នាំ ២០៣០ ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្មនឹងថយចុះមកត្រឹម ៥១ ៥៨៤ នាក់ (៨១,៦%) ក្នុងវិស័យឧស្សាហកម្មធុនស្រាលដែលជាសិប្បកម្មនឹងមានការកើនឡើងដល់ ៥១៣ នាក់ (០,៨%) ក្នុងវិស័យសេវាកម្មនឹងមានការកើនឡើងដល់ ១០ ០៨៣ នាក់ (១៦%) និងក្នុងវិស័យផ្សេងៗទៀតនឹងមាន ១ ០១៥ នាក់ (១,៦%)។

## ២.២-ចក្ខុវិស័យ

ចក្ខុវិស័យដល់ឆ្នាំ ២០៣០ នៃប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌គឺសំដៅរៀបចំនិងអភិវឌ្ឍស្រុកបរិបូណ៌ “ជាស្រុកគំរូក្នុងតំបន់បឹងទន្លេសាបលើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថានល្អប្រសើរប្រកបដោយចីរភាព តុល្យភាព និងបរិយាបន្ន” តាមរយៈការជំរុញ៖ ១)ការអភិវឌ្ឍតំបន់ទីប្រជុំជននិងតំបន់ជនបទប្រកបដោយសោភ័ណភាព អត្តសញ្ញាណ វប្បធម៌ និងធម្មជាតិល្អប្រសើរក្នុងភូមិសាស្ត្រតំបន់បឹងទន្លេសាប ២)ការអភិវឌ្ឍកសិកម្មនិងជលផលប្រកបដោយចំណេះដឹង ការច្នៃប្រឌិត និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ៣)ការអភិវឌ្ឍពាណិជ្ជកម្ម សេវាកម្ម ឧស្សាហកម្មសិប្បកម្មកែច្នៃ និងវិចខ្ចប់ផលិតផលកសិកម្មនិងជលផលសម្រាប់ការផ្គត់ផ្គង់ក្នុងស្រុកនិងការនាំចេញ ៤)ការអភិវឌ្ឍទេសចរណ៍វប្បធម៌និងធម្មជាតិតាមរយៈការលើកកម្ពស់ការរៀបចំនិងអភិរក្សតំបន់វប្បធម៌ប្រាសាទកំពង់ព្រះ តំបន់ធនធានធម្មជាតិអាងបឹងទន្លេសាបនិងតំបន់ជុំវិញ ស្ទឹងបរិបូណ៌ និងតំបន់ទេសភាពធម្មជាតិ ភ្នំនាងកង្រី និង ៥)ការលើកកម្ពស់អភិបាលកិច្ចល្អ ការថែរក្សាអត្តសញ្ញាណវប្បធម៌ជាតិ កិច្ចការពារធនធានធម្មជាតិ បរិស្ថាន និងការអភិវឌ្ឍបៃតង។

## ៣-គោលបំណងនិងគោលដៅនៃប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌មានគោលបំណងនិងគោលដៅដូចខាងក្រោម៖

### ៣.១-គោលបំណង

- តម្រង់ទិសការប្រើប្រាស់ដី ធនធានធម្មជាតិ និងការរៀបចំនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព ចីរភាព និងសមធម៌
- តម្រង់ទិសដល់ការអភិវឌ្ឍប្រវត្ត សេដ្ឋកិច្ច សង្គម និងធានាសន្តិសុខស្បៀង
- លើកកម្ពស់អត្តសញ្ញាណវប្បធម៌ជាតិ កិច្ចការពារបរិស្ថាន ការអភិវឌ្ឍបៃតង និងការបង្ការទប់ស្កាត់គ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- ជាមូលដ្ឋានដ៏សំខាន់សម្រាប់ការសម្រេចចិត្តរបស់អាជ្ញាធរមូលដ្ឋាននិងស្ថាប័ន អង្គភាពពាក់ព័ន្ធលើការអភិវឌ្ឍប្រវត្តប្រកបដោយប្រសិទ្ធភាពនិងមានការទទួលខុសត្រូវខ្ពស់។

### ៣.២-គោលដៅ

- កំណត់យុទ្ធសាស្ត្រអភិវឌ្ឍនគរូបនីយកម្មប្រកបដោយតុល្យភាព សមធម៌ និងចីរភាព
- កំណត់និងបែងចែកតំបន់ប្រើប្រាស់ដីស្របតាមសក្តានុពល មុខងារ សកម្មភាព និងការប្រើប្រាស់សម្រាប់គាំទ្រដល់ជីវភាពរស់នៅរបស់ប្រជាជនឱ្យបានល្អប្រសើរដូចជាតំបន់លំនៅឋាន កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ វប្បធម៌ប្រវត្តិសាស្ត្រ និងធនធានធម្មជាតិដើម្បីធ្វើការអភិវឌ្ឍ និងការអភិរក្សប្រកបដោយចីរភាព

- កំណត់ឱ្យបានច្បាស់លាស់ជាមុននូវតំបន់សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកែលម្អ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍធុរកិច្ច និងទាក់ទាញការគាំទ្រការវិនិយោគសាធារណៈនិងឯកជនដើម្បីសមធម៌សង្គមនិងផ្តល់ការងារដល់ប្រជាពលរដ្ឋក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ
- ធ្វើសមាហរណកម្មផែនការរូបវន្ត សេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងផែនការតាមវិស័យដើម្បីធានាភាពសុខដុមនីយកម្មសង្គមនិងការអភិវឌ្ឍប្រកបដោយចីរភាព
- ដោះស្រាយនិងឆ្លើយតបបានល្អតាមតម្រូវការរបស់ប្រជាពលរដ្ឋទូទៅនិងតម្រូវការគ្រប់គ្រងជាក់ស្តែងរបស់អាជ្ញាធរមានសមត្ថកិច្ច។

## ៤-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សស្រុកបរិបូណ៌ប្រកបដោយប្រសិទ្ធភាពនិងចីរភាព

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌បានកំណត់យុទ្ធសាស្ត្រអភិវឌ្ឍ អភិរក្ស គ្រប់គ្រងនិងប្រើប្រាស់ដី អភិបាលកិច្ចល្អ និងការធ្វើសមាហរណកម្មការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព សមធម៌ និងបរិយាបន្នដូចខាងក្រោម៖

### ៤.១-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សតំបន់ទីប្រជុំជននិងតំបន់ជនបទ

#### ៤.១.១-ការអភិវឌ្ឍនគរូបនីយកម្ម

- ជំរុញការកំណត់ព្រំប្រទល់រដ្ឋបាលស្រុក ឃុំ ភូមិ ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ
- ជំរុញកំណត់តំបន់ទីប្រជុំជន ការអភិវឌ្ឍនគរូបនីយកម្ម និងតំបន់ជនបទ
- ជំរុញដាក់លេខផ្ទះនិងឈ្មោះឬលេខផ្លូវដើម្បីងាយស្រួលក្នុងការគ្រប់គ្រង
- កែលម្អនិងស្តារហេដ្ឋារចនាសម្ព័ន្ធរួមមានផ្លូវ ទឹកស្អាត អគ្គិសនី ការប្រមូលសំណល់រឹងនិងរាវឱ្យមានលក្ខណៈសមស្របដើម្បីលើកកម្ពស់គុណភាពរស់នៅនិងសោភ័ណភាព
- ជំរុញការអភិវឌ្ឍដីឡូត៍ដែលមិនទាន់បានប្រើប្រាស់ឱ្យធ្វើការអភិវឌ្ឍនិងការប្រើប្រាស់ឱ្យបានចំទិសដៅនិងមុខងារប្រកបដោយចីរភាព
- កែលម្អនិងពង្រីកកំណាត់ផ្លូវជាតិលេខ ៥ ផ្លូវក្នុងតំបន់ទីប្រជុំជន ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយានចិញ្ចើមផ្លូវ ភ្លើងបំភ្លឺ ផ្លាកនិងគំនូសសញ្ញាចរាចរណ៍ ផ្លាកផ្សព្វផ្សាយពាណិជ្ជកម្ម កំណត់ប្រភេទដើមឈើនិងដាំដើមឈើ រៀបចំសួនច្បារតាមបណ្តោយផ្លូវ សួនសាធារណៈ សួនកុមារ ទីលានកីឡាកន្លែងកម្សាន្ត និងអភិវឌ្ឍផ្ទៃបៃតងនៅក្នុងស្រុកស្របទៅតាមតំបន់ប្រើប្រាស់ដីឱ្យមានសោភ័ណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ និងបរិស្ថានរស់នៅប្រកបដោយផាសុកភាព
- រៀបចំនិងកំណត់រចនាបថអគារនិងពណ៌អគារនិងរបងឱ្យមានសោភ័ណភាពល្អស្របតាមទីតាំងភូមិសាស្ត្រជាទីតាំងទេសចរណ៍ធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រ
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍដី ការសាងសង់និងប្លង់លម្អិតនគរូបនីយកម្មតាមតំបន់នីមួយៗ
- ការពារ កែលម្អ ស្តារ កសាងខឿនទប់ការបាក់ច្រាំង កំណត់និយាមកា កសាងផែនទីដីចំណីស្ទឹងបរិបូណ៌ អូរ បឹង និងចុះបោះបង្គោលព្រំដីចំណីស្ទឹង អូរ បឹង។

៤.១.២- ការកំណត់ទិសដៅនគរូបនីយកម្ម

- និន្នាការនៃការអភិវឌ្ឍទីប្រជុំជននិងនគរូបនីយកម្មមានលទ្ធភាពពង្រីកទៅកាន់តំបន់ភាគខាងលិច និងខាងជើងនៃទីប្រជុំជនស្រុកបរិបូណ៌បច្ចុប្បន្ន
- គ្រប់គ្រងការអភិវឌ្ឍនិងធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយប្រសិទ្ធភាព និងចីរភាពស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្មនិងការអភិវឌ្ឍរូបវន្ត ជាពិសេសបណ្តាញផ្លូវ ប្រព័ន្ធលូ អាងប្រព្រឹត្តកម្មទឹកកខ្វក់ និងចៀសវាងការសាងសង់មុនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ពង្រឹងសមត្ថភាពមន្ត្រីក្នុងការធ្វើផែនការអភិវឌ្ឍនិងគ្រប់គ្រងការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព ជាពិសេសគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពង់ឆ្នាំងដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំងជាសេនាធិការនិងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកបរិបូណ៌។

៤.១.៣- ការរៀបចំនិងការអភិវឌ្ឍតំបន់ជនបទ

- លើកកម្ពស់ការរៀបចំនិងការកែលម្អហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងសំណង់ផ្តល់សេវាជូនសាធារណជនមានជាអាទិ៍បណ្តាញផ្លូវ សាលារៀន មណ្ឌលសុខភាព អគាររដ្ឋបាលសាធារណៈ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតឱ្យមានសោភ័ណភាពល្អនិងទាក់ទាញដូចជាការដាំដើមឈើ ផ្កា អនាម័យ ថែរក្សានិងជួសជុលកែលម្អ។ល។
- លើកកម្ពស់ការរៀបចំនិងការកែលម្អដីឡូត៍និងលំនៅឋានប្រជាពលរដ្ឋឱ្យមានភាពបៃតងស្រស់បំព្រងដូចជាការដាំដើមឈើ ផ្កា ដំណាំហូបផ្លែ សួនបន្លែ បង្គន់អនាម័យ ការអនាម័យ ថែរក្សានិងជួសជុលកែលម្អ។ល។
- លើកកម្ពស់ការអភិរក្សនិងការថែរក្សាប្រាសាទកំពង់ព្រះ វត្តកំពង់ព្រះ និងវត្តអារាមនានាដើម្បីទាក់ទាញភ្ញៀវទេសចរដែលស្រឡាញ់វប្បធម៌និងសាសនា
- លើកកម្ពស់ការការពារនិងការថែរក្សាអត្តសញ្ញាណតំបន់ឆ្នុកទ្រូ ព្រៃលិចទឹក ស្ទឹងបរិបូណ៌ ទំនប់អាចាំង ទំនប់ ២០ ឧសភា ទំនប់លំហាច ស្ទឹង អូរ និងបណ្តាញផ្លូវទឹកដែលភ្ជាប់នឹងបឹងទន្លេសាប តំបន់កសិកម្មស្រូវប្រាំង និងទេសភាពធម្មជាតិក្នុងស្រុកបរិបូណ៌ដើម្បីទាក់ទាញភ្ញៀវទេសចរដែលស្រឡាញ់ធម្មជាតិ
- ធ្វើសមាហរណកម្មរវាងតំបន់ទីប្រជុំជននិងតំបន់ជនបទដោយធានាបាននូវតុល្យភាពនិងចីរភាពនៃការអភិវឌ្ឍនិងការអភិរក្ស។

៤.២- យុទ្ធសាស្ត្រគ្រប់គ្រងនិងប្រើប្រាស់ដី

ផ្អែកលើអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១១ ស្តីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧ ៤០៦ ហិកតា ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ដូច្នេះស្រុកបរិបូណ៌ត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺប្រភេទដីកម្រិតការសាងសង់និងប្រភេទដីអាចសាងសង់បាន។ យោងតាម

ការកំណត់ព្រំប្រទល់រដ្ឋបាលស្រុកបរិបូណ៌ដែលមានផ្ទៃដីសរុប ៤២ ៣០៩ ហិកតា ក្នុងនោះផ្ទៃដីត្រូវបានកំណត់ជាប្រភេទដីកម្រិតការសាងសង់មានទំហំ ៣៨ ៥៧១ ហិកតា ស្មើនឹង ៩១,១៧% និងប្រភេទដីអាចសាងសង់បានមានទំហំ ៣ ៧៣៧ ហិកតា ស្មើនឹង ៨,៨៣%។

### ៤.២.១-ប្រភេទដីកម្រិតការសាងសង់

១) តំបន់ការពារធម្មជាតិនិងជីវចម្រុះបឹងទន្លេសាបៈ យោងអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១១ ស្តីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧ ៤០៦ ហិកតា ស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប និងសៀវភៅស្តីពីការបោះបង្គោលការពារព្រៃលិចទឹកជុំវិញបឹងទន្លេសាបបានកំណត់ថា បឹងទន្លេសាបគឺជាបឹងដែលធំជាងគេបង្អស់ក្នុងតំបន់អាស៊ីអាគ្នេយ៍ សម្បូរធនធានធម្មជាតិជីវចម្រុះក្នុងទឹកជាច្រើនប្រភេទ និងមានតំបន់ទំនាបនៅជុំវិញមាត់បឹងដែលកំណត់ជាតំបន់ព្រៃលិចទឹកនៅរដូវវស្សា។ ដោយឡែកស្រុកបរិបូណ៌ដែលមានតំបន់ការពារជីវចម្រុះត្រូវបានកំណត់ដូចខាងក្រោមៈ

- ផ្ទៃបឹងទន្លេសាបចាំបាច់ត្រូវការពារនិងថែរក្សាជីវចម្រុះធម្មជាតិ ប្រើប្រាស់ជាគោលដៅទេសចរណ៍ធម្មជាតិ កំពង់ផែ ផ្លូវដឹកជញ្ជូន ប្រភពទឹកស្អាត និងទឹកស្រោចស្រព
- ផ្ទៃដីតំបន់ ៣ ដែលជាតំបន់ការពារព្រៃលិចទឹកបឹងទន្លេសាប មានទំហំប្រមាណ ៨ ៩៣១ ហិកតា ត្រូវបានការពារនិងទប់ស្កាត់ការកាប់បំផ្លាញ ការទន្ទ្រានយកដី ការនេសាទខុសច្បាប់ ការបរបាញ់សត្វគ្រប់ប្រភេទដើម្បីរក្សាព្រៃលិចទឹកសម្រាប់ចីរភាពបរិស្ថាន។

២) តំបន់សហគមន៍ព្រៃឈើៈ រដ្ឋបាលស្រុកបរិបូណ៌និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំងបានកំណត់តំបន់ការពារធំៗចំនួន ៣ កន្លែង មានផ្ទៃដីប្រមាណ ២ ៩៣១ ហិកតា ស្ថិតនៅឃុំត្រពាំងចាន់ ឃុំអញ្ចាញរូង និងឃុំពេជចង្វារ។ តំបន់ទាំងនេះទាមទារឱ្យមានការការពារយ៉ាងសកម្ម និងត្រូវមានការអភិវឌ្ឍដែលមានលក្ខណៈសមស្របជាមួយបរិស្ថានក្នុងតំបន់ ពីព្រោះតំបន់ទាំងនេះផ្តល់នូវសក្តានុពលទេសចរណ៍ ផ្សារភ្ជាប់ជាមួយវិធានការដោះស្រាយទឹកសម្រាប់ការដាំដុះ ចិញ្ចឹមសត្វ និងការរស់នៅរបស់ប្រជាជនក្នុងតំបន់។ មួយផ្នែកទៀតជាតំបន់ព្រៃលិចទឹកដែលមានផ្ទៃដីប្រមាណ ៨ ៩៣១ ហិកតាដែលបច្ចុប្បន្នកំពុងតែទទួលរងនូវការកាប់គាស់រានដើម្បីធ្វើការដាំដុះដំណាំស្រូវប្រាំងនិងត្រូវទាមទារឱ្យមានការការពារយ៉ាងម៉ឺងម៉ាត់ ព្រោះតំបន់នេះពាក់ព័ន្ធដល់បរិស្ថានជលផល និងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់លិចទឹកដែលអាចមានសក្តានុពលសម្រាប់ប្រព័ន្ធស្រោចស្រពគាំទ្រដល់តំបន់កសិកម្ម។

៣) តំបន់ការពារធម្មជាតិ (ស្ទឹង បឹង អូរ ប្រឡាយ ត្រពាំង)ៈ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង និងអាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្តឱ្យបានត្រឹមត្រូវស្របតាមបទដ្ឋានគតិយុត្តជាធរមានក្នុងការការពារដីសាធារណៈរបស់រដ្ឋមានជាអាទិ៍ស្ទឹង បឹង អូរ ប្រឡាយ ត្រពាំងដើម្បីជាប្រយោជន៍ដល់ប្រជាជនទូទៅនិងសង្គម។

៤) ប្រព័ន្ធស្រោចស្រពកសិកម្ម៖ ប្រព័ន្ធធារាសាស្ត្រក្នុងស្រុកបរិបូណ៌ មានចំនួន ២ ធំៗរួមមានប្រព័ន្ធធារាសាស្ត្រអាចាំងនិងប្រព័ន្ធធារាសាស្ត្រដែលបានផ្តល់ការស្រោចស្រពដ៏សម្បូរបែបសម្រាប់ប្រើប្រាស់គាំទ្រដល់វិស័យកសិកម្មក្នុងស្រុកបរិបូណ៌ ក៏ដូចជាខេត្តកំពង់ឆ្នាំង ព្រោះផលិតផលកសិកម្មគឺជាធាតុដ៏សំខាន់ក្នុងការផ្តល់ស្បៀងអាហារ ត្រីសាច់សម្រាប់ប្រជាជននិងភ្ញៀវទេសចរជាតិនិងអន្តរជាតិដែលមកទស្សនានៅខេត្តកំពង់ឆ្នាំង។

៥) តំបន់កសិកម្ម៖ តំបន់ប្រើប្រាស់ដីកសិកម្ម មានផ្ទៃដីប្រមាណ ២៦ ៦៣៩ ហិកតា ស្មើនឹង ៦២,៩៦% នៃផ្ទៃដីស្រុកបរិបូណ៌មានជាអាទិ៍ស្រែស្រូវ ចំការស្វាយ។ ក្នុងសេចក្តីត្រូវការចាំបាច់សម្រាប់ដំណាំដាំដុះគឺត្រូវការយកចិត្តទុកដាក់កែលម្អប្រព័ន្ធស្រោចស្រពដែលមានស្រាប់និងប្រព័ន្ធស្រោចស្រពថ្មីដើម្បីស្តុកទឹកសម្រាប់ប្រើប្រាស់ឱ្យបានគ្រប់រដូវ។ តំបន់នេះត្រូវបានបែងចែកជា ២ ប្រភេទគឺ៖

- តំបន់ស្រែវស្សា លាតសន្ធឹងតាមដងផ្លូវជាតិលេខ ៥ រហូតដល់ព្រំប្រទល់ខាងលិចនៃស្រុក។ ទីតាំងនេះផ្តល់នូវដីកសិកម្មដែលមានជីជាតិមធ្យម និងលទ្ធភាពសម្រាប់កសាងនិងស្តារប្រព័ន្ធស្រោចស្រពក្នុងតំបន់នេះដោយការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវស្ទឹង អូរ និងប្រឡាយដែលមានស្រាប់។ ដំណាំដាំដុះសមស្របសម្រាប់តំបន់នេះរួមមានដំណាំស្រូវ ដំណាំស្វាយចន្ទី ខ្នុរ។ល។
- តំបន់ស្រែប្រាំង លាតសន្ធឹងពីផ្លូវជាតិលេខ ៥ រហូតដល់មាត់បឹងទន្លេសាប។ ទីតាំងនេះផ្តល់នូវដីកសិកម្មមានជីជាតិល្អ ដោយសារតំបន់នេះទទួលនូវរបបទឹកទន្លេសាប និងគួរសាងសង់ប្រព័ន្ធស្រោចស្រព ឬទំនប់ស្តុកទឹកសម្រាប់ប្រើប្រាស់ឱ្យបានសមស្រប។

៦) តំបន់អាជីវកម្មធនធានខ្សាច់៖ តំបន់សម្រាប់ការធ្វើអាជីវកម្មធនធានខ្សាច់មានផ្ទៃដីប្រមាណ ៧០,០ ហិកតា ត្រូវការពារនិងថែរក្សាជាទ្រព្យសាធារណៈរបស់រដ្ឋដោយមិនអនុញ្ញាតឱ្យមានការកាន់កាប់និងសាងសង់។ រាល់ការវិនិយោគអាជីវកម្មធនធានខ្សាច់ពីដងស្ទឹងបរិបូណ៌ត្រូវធានាបាននូវចីរភាពសុខដុមណីយកម្ម និងផលប្រយោជន៍សាធារណៈ។

### ៤.២.២- ប្រភេទដីអាចសាងសង់បាន

ផ្អែកតាមផែនទីប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ចក្ខុវិស័យឆ្នាំ ២០៣០ ប្រភេទដីអាចសាងសង់បានត្រូវបានកំណត់ជា ១០ តំបន់។ បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់នីមួយៗត្រូវមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សន្ទស្សន៍ប្រើប្រាស់ដី សួនច្បារជ្រាបទឹក ការដាំដើមឈើ ជួរតម្រង់ ថ្លាគម្លាត កម្ពស់ ចំណតរថយន្ត អាងបង្គន់អនាម័យ អាងប្រព្រឹត្តកម្មទឹកកខ្វក់ ពណ៌អគារ សោភ័ណភាព និងរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរនិងលក្ខណៈធម្មជាតិត្រឹមត្រូវស្របតាមបទប្បញ្ញត្តិជាធរមាន ដោយបែងចែកជាតំបន់ប្រើប្រាស់ដីដូចខាងក្រោម៖

១) តំបន់លំនៅឋានជាតំបន់ដែលបានបែងចែកសម្រាប់ប្រជាជនរស់នៅ និងមានផ្ទៃដីប្រមាណ ១ ៨១៧ ហិកតា ស្មើនឹង ៤,៣០%។ តំបន់លំនៅឋានត្រូវបានបែងចែកចេញជាតំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់ មធ្យម និងទាបដូចខាងក្រោម៖

- តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់ ស្ថិតនៅជុំវិញតំបន់ពាណិជ្ជកម្មនិងតំបន់ប្រើប្រាស់ចម្រុះក្នុងទីប្រជុំជនពន្លៃ លាតសន្ធឹងនៅតាមបណ្តោយកំណាត់ផ្លូវជាតិលេខ ៥ រហូតដល់ស្ទឹងបរិបូណ៌និងមានផ្ទៃដី ៦៣៦ ហិកតា ស្មើនឹង ១,៥០% ព្រមទាំងត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ៣,០។

○ តំបន់លំនៅឋានដែលមានកម្ពស់មធ្យម ស្ថិតនៅព័ទ្ធជុំវិញតំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់តាមបណ្តោយកំណាត់ផ្លូវជាតិលេខ ៥ និងតាមផ្លូវថ្មីគ្រោងវាងទីប្រជុំជនពន្លៃប្រវែងប្រមាណ ១៩ គីឡូម៉ែត្រដែលបានស្នើឡើងនៅផ្នែកខាងត្បូងនៃទីប្រជុំជនស្រុក និងមានផ្ទៃដី ៥៤៤ ហិកតា ស្មើនឹង ១,២៩% ព្រមទាំងត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ៣,០។

○ តំបន់លំនៅឋានដែលមានកម្ពស់ទាប ស្ថិតនៅព័ទ្ធជុំវិញតំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់និងមធ្យម និងតាមបណ្តោយផ្លូវក្នុងស្រុក និងមានផ្ទៃដី ៦៣៧ ហិកតា ស្មើនឹង ១,៥១% ព្រមទាំងត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ១,៥។

២) តំបន់ពាណិជ្ជកម្ម មានផ្ទៃដីប្រមាណ ៥៧ ហិកតា ស្មើនឹង ០,១៣% ស្ថិតនៅឃុំពន្លៃ ដែលជាទីប្រជុំជនស្រុកបរិបូណ៌សព្វថ្ងៃនិងអនាគត ជាពិសេសជាចំណុចបំបែករវាងផ្លូវជាតិលេខ ៥ (ផ្លូវអាស៊ានហាយវេលេខ ១) និងផ្លូវជាតិលេខ ៥២។ តំបន់នេះកំពុងមានការអភិវឌ្ឍរីកចម្រើនលឿនដោយត្រូវមានការរឹតបន្តឹងតាមលំដាប់លំដោយនូវតួនាទីនៃផ្នែកជំនួញ និងសេវាកម្មនានាដែលត្រូវមានការជំរុញបន្ថែម ជាពិសេសសេវាកម្មភោជនីយដ្ឋាន អាហារដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់សម្រាប់ភ្ញៀវធ្វើដំណើរឆ្លងកាត់និងមកកម្សាន្ត។ ដើម្បីចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ការកំណត់តំបន់សម្រាប់ធ្វើពាណិជ្ជកម្មក្នុងស្រុកនឹងជួយសម្រួលដល់ការលើកកម្ពស់ជីវភាពប្រជាជននៅមូលដ្ឋាន ដោយផ្តោតលើការកែលម្អផ្សារនិងទីតាំងផ្តល់សេវាកម្មផ្សេងៗក្នុងទីប្រជុំជនតាមដងផ្លូវដែលជាច្រកសេដ្ឋកិច្ចជាតិនិងអន្តរជាតិ (ផ្លូវជាតិលេខ ៥) ដ៏សំខាន់នេះ។ តំបន់ពាណិជ្ជកម្មត្រូវបានបែងចែកជា៖

○ តំបន់ពាណិជ្ជកម្មត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ៦,០

○ តំបន់ពាណិជ្ជកម្មចម្រុះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ៥,០។

៣) តំបន់ឧស្សាហកម្មនិងសិប្បកម្ម មានផ្ទៃដីប្រមាណ ១៤៧ ហិកតា ស្មើនឹង ០,៣៥% មានជាអាទិ៍រោងចក្រទឹកកក ម៉ាស៊ីនកិនស្រូវ កន្លែងបិទស្រា ហាងនំប៉័ង កន្លែងកែច្នៃគ្រឿងសង្ហារឹមពីឈើនិងដែក កន្លែងកិនសំងួសី កន្លែងធ្វើទូកនេសាទ កន្លែងផលិតទឹកសុទ្ធ កន្លែងដេរផុង និងសិប្បកម្មកែច្នៃដទៃទៀតមានចំនួន ១៩៥ កន្លែងដែលត្រូវរៀបចំនិងលើកទឹកចិត្តឱ្យមានអ្នកវិនិយោគលើផ្នែកឧស្សាហកម្មកែច្នៃផលិតផលកសិកម្មនិងផលិតផលនេសាទ។ តំបន់ឧស្សាហកម្មនិងសិប្បកម្មត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ៣,០។

៤) តំបន់រដ្ឋបាលនិងសេវាសាធារណៈ មានផ្ទៃដីប្រមាណ ១២ ហិកតា ស្មើនឹង ០,១៣% ស្ថិតក្នុងឃុំពន្លៃមានជាអាទិ៍សាលាស្រុក ការិយាល័យ អង្គភាពជុំវិញស្រុក ទីបញ្ជាការដ្ឋាន អធិការដ្ឋាន សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព។ តំបន់រដ្ឋបាលត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ៥,០។

៥) តំបន់លំហសាធារណៈនិងផ្ទៃបៃតង មានផ្ទៃដីប្រមាណ ៨៩៩ ហិកតា ស្មើនឹង ២,១២% មានជាអាទិ៍សួនច្បារ លំហសាធារណៈ ទីលានកីឡដ្ឋាន សួនតាមបណ្តោយស្ទឹងបរិបូណ៌។ តំបន់លំហសាធារណៈនិងផ្ទៃបៃតងត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ០,១។

៦) តំបន់ទេសចរណ៍ មានផ្ទៃដីប្រមាណ ៤៣ ហិកតា ស្មើនឹង ០,១០% និងត្រូវបានចែកចេញជាតំបន់ទេសចរណ៍ធម្មជាតិនិងតំបន់ទេសចរណ៍សេវាកម្ម។ តំបន់នេះស្ថិតនៅតាមទីតាំងផ្សេងៗនៅក្នុងស្រុកបរិបូណ៌។ តំបន់ទេសចរណ៍ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ១,០។

៧) តំបន់ចម្រុះ មានផ្ទៃដីប្រមាណ ៥៩១ ហិកតា ស្មើនឹង ១,៤០% និងមាននៅតំបន់ដែលមានមុខងារប្រើប្រាស់ច្រើនយ៉ាងដូចជាភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ និងសេវាកម្មផ្សេងៗ។ តំបន់នេះត្រូវបានយកចិត្តទុកដាក់ដោយធានាបាននូវបរិស្ថានល្អនិងរក្សាផ្ទៃបៃតងឱ្យបានសមស្រប។ តំបន់ចម្រុះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ៥,០។

៨) តំបន់ដឹកជញ្ជូន មានផ្ទៃដីប្រមាណ ១៤ ហិកតា ស្មើនឹង ០,០៣% មានជាអាទិ៍បណ្តាញផ្លូវ កំពង់ផែ ព្រលានយន្តហោះ ស្ថានីយរថភ្លើង។ តំបន់នេះទាមទារឱ្យមានការការពារនិងការពង្រីកដោយយកចិត្តទុកដាក់ដោយសារអាចនាំមកនូវសេដ្ឋកិច្ចយ៉ាងសំខាន់ដល់ស្រុកបរិបូណ៌។

៩) តំបន់វប្បធម៌និងសាសនា មានផ្ទៃដីប្រមាណ ៥១ ហិកតា ស្មើនឹង ០,១២% មានជាអាទិ៍វត្តអារាមព្រះពុទ្ធសាសនា វិហារសាសនា ទីសក្ការបូជានានា។ តំបន់វប្បធម៌និងសាសនាត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ២,០ និងរក្សាផ្ទៃបៃតងឱ្យបានសមស្រប។

១០) តំបន់ចាក់សំរាម មានផ្ទៃដីប្រមាណ ១២ ហិកតា ស្មើនឹង ០,០៣%។

## ៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធត្រូវតែពង្រឹងនិងលើកកម្ពស់ឱ្យដល់កម្រិតសម្រាប់បម្រើដល់វិស័យកសិកម្ម ទេសចរណ៍ សេដ្ឋកិច្ច និងសង្គមក្នុងស្រុកបរិបូណ៌រួមមាន៖

### ៤.៣.១-ផ្លូវគោក

- កែលម្អផ្លូវដែលមានស្រាប់មួយចំនួនដើម្បីផ្តល់ភាពងាយស្រួលដល់ការធ្វើដំណើរទៅមកនិងការដឹកជញ្ជូនទំនិញ ផលិតផលកសិកម្មនិងនេសាទ និងការចូលទៅកាន់តំបន់ទេសចរណ៍
- កែលម្អផ្លូវដែលមានស្រាប់ដោយផ្តល់អាទិភាពលើកំណាត់ផ្លូវជាតិលេខ ៥ ផ្លូវជាតិលេខ ៥២ និងផ្លូវឆ្ពោះទៅកាន់ផ្លូវដែកដែលជាច្រករបៀងសេដ្ឋកិច្ចសំខាន់
- កែលម្អផ្លូវជាតិលេខ ៥៣ អា ចេញពីឃុំផ្សារកាត់តាមឃុំអញ្ចាញរូងរហូតដល់ផ្លូវដែក
- បង្កើតផ្លូវដឹកជញ្ជូនថ្មីមួយខ្សែវាងទីប្រជុំជន មានទំហំ ៥០ ម៉ែត្រ និងប្រវែង ១៩ គីឡូម៉ែត្រចាប់ពីឃុំផ្សារទៅដល់អន្លង់ចិបក់ ខេត្តពោធិ៍សាត់ដើម្បីបញ្ចៀសចរាចរណ៍ក្នុងតំបន់ទីប្រជុំជនពន្លេ ក៏ដូចជាកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍
- កសាងបណ្តាញផ្លូវថ្មីបន្ថែមនៅក្នុងទីប្រជុំជននិងតំបន់លំនៅឋានដែលបានកំណត់ក្នុងការអភិវឌ្ឍនាពេលអនាគតនិងតភ្ជាប់កំណាត់ផ្លូវដែលទាល់
- ផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍តាមផ្លូវគោក។

### ៤.៣.២- ផ្លូវទឹក

- កសាងកំពង់ផែដ៏ស្រស់ស្អាតជាមួយនឹងមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ ដោយស្តារផ្លូវទឹកដើម្បីឱ្យទូកទេសចរណ៍ ឬនាវាទេសចរណ៍ ឬនាវាដឹកជញ្ជូនអាចចូលចតបាន នៅឃុំឆ្នុកទ្រូ
- កសាងចំណតទូកនេសាទដើម្បីគ្រប់គ្រងការនេសាទនៅតំបន់ឆ្នុកទ្រូនិងរក្សាសណ្តាប់ធ្នាប់របៀបរៀបរយនៅបឹងទន្លេសាប។

### ៤.៣.៣- ទឹកស្អាតនិងធនធានទឹក

- រៀបចំឱ្យមានប្រព័ន្ធទឹកស្អាតដោយយកចិត្តទុកដាក់លើគុណភាពនិងបរិមាណ
- លើកទឹកចិត្តឱ្យមានការវិនិយោគលើវិស័យទឹកស្អាតដោយប្រើប្រាស់ប្រភពទឹកបឹងទន្លេសាប
- សិក្សាប្រភពទឹកផ្សេងៗដើម្បីផ្គត់ផ្គង់ទឹកស្អាតសម្រាប់ស្រុកដោយចៀសវាងការប្រើប្រាស់ប្រភពទឹកក្រោមដី
- រៀបចំបទប្បញ្ញត្តិនិងចាត់វិធានការក្នុងការការពារនិងថែរក្សាប្រភពផ្គត់ផ្គង់ទឹក។

### ៤.៣.៤- ថាមពលអគ្គិសនី ទូរគមនាគមន៍ និងព័ត៌មានវិទ្យា

- ពង្រីកបន្ថែមបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិនិងគ្រប់លំនៅឋាន
- បន្តនិងជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ
- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូរគមនាគមន៍និងប្រព័ន្ធព័ត៌មានវិទ្យាដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចទេសចរណ៍ និងពាណិជ្ជកម្ម
- រៀបចំ ជួសជុល កែលម្អ និងសាងសង់បង្គោលភ្លើងនិងប្រព័ន្ធខ្សែភ្លើងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដោយចៀសវាងការបង្កគ្រោះថ្នាក់និងការបាត់បង់សោភ័ណភាព។

## ៤.៤- យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច

### ៤.៤.១- យុទ្ធសាស្ត្រអភិវឌ្ឍកសិកម្មនិងផ្សព្វផ្សាយផលិតផលក្នុងស្រុក

- ថែរក្សានិងការពារដីកសិកម្ម ស្រែ ចម្ការ និងពង្រីកដីដាំដុះបន្ថែមឱ្យមានប្រសិទ្ធភាពនិងចីរភាពដើម្បីធានាសន្តិសុខស្បៀង
- កែលម្អនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់កសិកម្មមានជាអាទិ៍ប្រព័ន្ធធារាសាស្ត្រ អាងស្តុកទឹក ផ្លូវដឹកជញ្ជូន
- បង្កើនសមត្ថភាពនៅថ្នាក់មូលដ្ឋានសំដៅផ្តល់នូវចំណេះដឹងនិងជំនាញដល់កសិករ
- ជំរុញឱ្យមានសុវត្ថិភាពនៃផលិតកម្ម ជំរុញការអភិវឌ្ឍកសិកម្មបែបទំនើប និងជំរុញការប្រើប្រាស់បច្ចេកវិទ្យាឆ្លាតវៃនិងឪជីថល
- ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិនិងពង្រីកទីផ្សារផលិតផលកសិកម្មនិងនេសាទ

- ជំរុញការធ្វើកសិកម្មសរីរាង្គដោយប្រើជីធម្មជាតិសម្រាប់ការប្រើប្រាស់ក្នុងតំបន់និងការនាំចេញ
- បង្កបរិយាកាសល្អ លើកទឹកចិត្ត និងជំរុញការវិនិយោគក្នុងស្រុកនិងក្រៅស្រុកលើកសិកម្មនិងនេសាទ ដើម្បីគាំទ្រដល់ទេសចរណ៍និងអភិវឌ្ឍសេដ្ឋកិច្ច
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយនិងមណ្ឌលព័ត៌មានអំពីស្តង់ដាបច្ចេកទេសកសិកម្មដល់ប្រជាពលរដ្ឋ
- បង្កើនផលិតភាព គុណភាព និងពិពិធកម្មតាមរយៈការបង្កើនការវិនិយោគលើការស្រាវជ្រាវនិងការអភិវឌ្ឍពូជដំណាំ ពូជសត្វ និងការចិញ្ចឹមត្រី
- បន្តអនុវត្តច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ក្របខណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបសុសត្វឆ្នាំ ២០១៦-២០២៥ និងផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍវារីវប្បកម្មឆ្នាំ ២០១៦-២០៣០។

សេចក្តីត្រូវការចាំបាច់សម្រាប់ជំរុញការដាំដុះ គឺត្រូវយកចិត្តទុកដាក់កែលម្អប្រព័ន្ធស្រោចស្រពដែលមានស្រាប់និងប្រព័ន្ធស្រោចស្រពថ្មីដើម្បីស្តុកទឹកទុកបំរុងសម្រាប់ស្រោចស្រពឱ្យបានគ្រប់រដូវនិងពង្រឹងការផ្សព្វផ្សាយពីបច្ចេកទេសកសិកម្មឱ្យបានទូលំទូលាយ និងប្រើប្រាស់ដីកសិកម្មឱ្យអស់លទ្ធភាព ព្រមទាំងសិក្សាពីគុណភាពដីដើម្បីជ្រើសរើសប្រភេទដំណាំដាំដុះឱ្យបានសមស្របសំដៅបង្កើនផលិតផលសម្រាប់ផ្គត់ផ្គង់ក្នុងស្រុកនិងសម្រាប់កែច្នៃនាំចេញ។ ទន្ទឹមនេះត្រូវខិតខំបំផុសឱ្យប្រជាជនចេះប្រើប្រាស់ជីធម្មជាតិលើដំណាំកសិកម្មសម្រាប់ផ្គត់ផ្គង់ដល់ភ្ញៀវទេសចរនៅនឹងកន្លែង និងទទួលទានបន្លែផ្លែឈើដែលគ្មានជាតិគីមីដោយចៀសវាងការនាំចូលពីក្រៅស្រុក។

ប្រព័ន្ធធារាសាស្ត្រអាចាំងមានប្រវែង ១៩,៥ គីឡូម៉ែត្រឆ្លងកាត់ឃុំអញ្ចាញរូង ផ្សារ ពេជចង្វារ ពពេល ពន្លៃចក ខុនរ៉ង ឆ្នុកទ្រ និងឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ និងឃុំក្រាំងស្គារ ស្រុកទឹកផុស ក្នុងខេត្តកំពង់ឆ្នាំង។ ប្រព័ន្ធស្រោចស្រពទាំងនេះអាចធ្វើការស្រោចស្រពលើផ្ទៃដីកសិកម្មបានប្រមាណ ១១ ០០០ ហិកតា។

ដើម្បីងាយស្រួលរកទីផ្សារសម្រាប់ផលិតផលកសិកម្ម ប្រជាពលរដ្ឋគួរចងក្រងជាសហគមន៍ដាំដំណាំកសិកម្ម តាមបែបភូមិមួយផលិតផលមួយដូចជារួមគ្នាដាំដំណាំពូជស្រូវណាដែលផ្តល់ផលតាមស្តង់ដាទីផ្សារនិងក្រោយពីច្រូតកាត់រួចនៅលើផ្ទៃដីស្រែទាំងនោះត្រូវរួមគ្នាដាំដំណាំឆ្លាស់ផ្សេងៗទៀតដូចជាពោត សណ្តែក ល្ង ដែលត្រូវការទឹកស្រោចស្រពតិចជាងដំណាំស្រូវឱ្យបានបរិមាណខ្ពស់និងតាមស្តង់ដាដើម្បីបំពេញតម្រូវការទីផ្សារក្នុងស្រុកនិងការនាំចេញ។

ទន្ទឹមគ្នានេះដែរ ត្រូវជំរុញការចិញ្ចឹមសត្វដោយត្រូវស្វែងរកពូជសត្វ និងកែលម្អសេវាបសុពេទ្យាបាល ព្រមទាំងពង្រីកវិសាលភាពបសុព្យាបាលតាមរយៈការចាក់ថ្នាំបង្ការនិងការផ្សព្វផ្សាយ ឬការបណ្តុះបណ្តាលការយល់ដឹងដល់កសិករ ព្រោះជម្ងឺសត្វជាឧបសគ្គដ៏ចម្បង។

### ៤.៤.២-យុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍

វិស័យទេសចរណ៍ត្រូវបានចាត់ទុកជាឧស្សាហកម្មគ្មានផ្សែងដែលជំរុញឱ្យសេដ្ឋកិច្ចជាតិមានសន្ទុះកំណើនទៅមុខតាមរយៈការផ្តល់ការងារធ្វើ ការផ្តល់រូបិយប័ណ្ណបរទេសចូលក្នុងថវិការដ្ឋ។ ការផ្តល់សេវាកម្មទេសចរណ៍គឺជាយុទ្ធសាស្ត្រអាទិភាពសម្រាប់ការអភិវឌ្ឍលើវិស័យទេសចរណ៍ដោយត្រូវចាប់ផ្តើមយកចិត្តទុកដាក់ពីការកសាង

រមណីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះលំហែ ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន។ ចំណុចសំខាន់មួយទៀតគឺការជំរុញកសាងនិងកែលម្អបណ្តាញផ្លូវ ជាពិសេសផ្លូវជាតិលេខ ៥២ តភ្ជាប់ពីទីប្រជុំជនស្រុកបរិបូណ៌មកឃុំឆ្នុកទ្រូ និងផ្លូវក្នុងស្រុកដែលអាចផ្តល់ប្រយោជន៍ដល់វិស័យនេះ។ ទន្ទឹមគ្នានេះដែរត្រូវជំរុញថែទាំនិងការពារប្រាសាទកំពង់ព្រះឱ្យបានគង់វង្សដែលជាសក្តានុពលសម្រាប់បម្រើដល់ទេសចរណ៍វប្បធម៌ ក៏ដូចជាជំរុញការអភិរក្សព្រៃលិចទឹកដែលមានសម្រស់ធម្មជាតិទាក់ទាញដ៏ស្រស់ត្រកាល និងការពារទីតាំងជម្រកត្រីពងសម្រាប់ភ្ញៀវទេសចរទស្សនាលំហែកម្សាន្ត។

កត្តាចម្បងមួយទៀតគឺការអភិវឌ្ឍធនធានមនុស្សបម្រើវិស័យទេសចរណ៍ដោយយកចិត្តទុកដាក់ឱ្យបានខ្លាំងក្នុងការធ្វើឱ្យមានសមត្ថភាពល្អប្រសើរដល់មគ្គុទ្ទេសទេសចរណ៍ និងការបណ្តុះបណ្តាលនិងអភិវឌ្ឍជំនាញវិជ្ជាជីវៈស្របតាមស្តង់ដាជាតិនិងអន្តរជាតិ។

ការផ្សព្វផ្សាយឱ្យបានទូលំទូលាយទាំងក្នុងនិងក្រៅប្រទេសអំពីកន្លែងទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិដែលមាននៅក្នុងស្រុកបរិបូណ៌ ជាពិសេសព្រៃលិចទឹកជាកិច្ចការចំពោះមុខនិងយូរអង្វែងដែលត្រូវអនុវត្តដើម្បីឱ្យចរន្តសេដ្ឋកិច្ចស្រុកបរិបូណ៌កាន់តែមានភាពខ្លាំងក្លាថែមទៀត។ ការផ្សព្វផ្សាយនេះអាចអនុវត្តទៅបានជោគជ័យប្រសិនបើមានការចូលរួមពីផ្នែកឯកជន ជាពិសេសក្រុមហ៊ុនទេសចរណ៍។

តំបន់ទេសចរណ៍ដែលមានសក្តានុពលក្នុងស្រុកបរិបូណ៌រួមមានប្រាសាទកំពង់ព្រះ ប្រព័ន្ធធារាសាស្ត្រអាចាំងប្រព័ន្ធធារាសាស្ត្រ ២០ ឧសភា ស្ទឹងបរិបូណ៌ តំបន់ព្រៃលិចទឹក និងតំបន់សហគមន៍ព្រៃឈើ។

- ប្រាសាទកំពង់ព្រះៈ ដើម្បីទៅដល់ប្រាសាទកំពង់ព្រះ ភ្ញៀវទេសចរត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ ៥ និងផ្លូវលំដែលមានចម្ងាយប្រមាណ ៤៤ គីឡូម៉ែត្រ។ ប្រាសាទនេះស្ថិតនៅក្នុងភូមិកំពង់ព្រះ ឃុំឆ្នុកទ្រូ ស្រុកបរិបូណ៌ នៅលើទីទួលមួយក្នុងបរិវេណវត្តកំពង់ព្រះដែលពីបុរាណកាលមកតែងហៅតៗគ្នាថា "វត្តទួលព្រះស្រីពិជ័យសួរវង្សកំពង់ព្រះ" ដែលនៅលើទីទួលនេះមានប្រាសាទចំនួន ២ គឺប្រាសាទប្រុសនិងប្រាសាទស្រី
- ប្រព័ន្ធធារាសាស្ត្រអាចាំងមានប្រវែងប្រមាណ ១៩,៥ គីឡូម៉ែត្រឆ្លងកាត់ឃុំអញ្ចាញរូង ផ្សារ ពេជចង្វារ ពពេល ពន្លៃ ចក ខុនរ៉ង ឆ្នុកទ្រូ និងឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ និងឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ ប្រព័ន្ធធារាសាស្ត្រនេះក៏ជាកន្លែងដ៏មានប្រជាប្រិយភាពសម្រាប់ប្រជាជននៅក្នុងស្រុកបរិបូណ៌ ក៏ដូចជាក្នុងខេត្តកំពង់ឆ្នាំងទៅលេងកម្សាន្ត
- តំបន់ព្រៃលិចទឹក មានផ្ទៃដី ៨ ៩៣១ ហិកតាដែលគួរត្រូវបានរក្សាទុកឱ្យបានស្ថិតស្ថេរគង់វង្សដើម្បីធ្វើជាតំបន់ទេសចរណ៍បែបធម្មជាតិយ៉ាងសម្បូរបែបនាពេលអនាគត
- តំបន់សហគមន៍ព្រៃឈើ មានចំនួន ៣ កន្លែងនិងមានផ្ទៃដី ២ ៩៣១ ហិកតា ស្ថិតនៅក្នុងឃុំត្រពាំងចាន់ និងឃុំពេជចង្វារ។ តំបន់នេះនឹងផ្តល់សក្តានុពលទេសចរណ៍យ៉ាងសម្បូរបែបនាពេលអនាគត
- ប្រព័ន្ធធារាសាស្ត្រ ២០ ឧសភា ជាទីតាំងប្រវត្តិសាស្ត្រ ស្ថិតនៅក្នុងស្រុកបរិបូណ៌និងស្រុករលាប្អៀរ និងបានផ្តល់ជាប្រភពទឹកសម្រាប់កសិកម្មនិងជាតំបន់ទេសចរណ៍បែបធម្មជាតិ។

## ៤.៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍពាណិជ្ជកម្ម

- រៀបចំទីតាំងផ្សារនិងតំបន់ពាណិជ្ជកម្មមានស្រាប់ឱ្យមានច្រកផ្លូវចេញចូល បរិស្ថានល្អ កន្លែងទុកដាក់សំរាម លូបង្ហូរទឹកកខ្វក់ ចំណតរថយន្ត កន្លែងលើកដាក់ទំនិញ កន្លែងភ្ញៀវឡើងចុះរថយន្ត ភ្លើងបំភ្លឺ ផ្លាកសញ្ញាចរាចរណ៍ សួនច្បារ និងផ្លូវថ្មើរជើង

- រៀបចំបទប្បញ្ញត្តិសម្រាប់ការសាងសង់ក្នុងតំបន់ពាណិជ្ជកម្មដើម្បីឆ្លើយតបតាមតម្រូវការជាក់ស្តែង
- រៀបចំ ពង្រីកបន្ថែម និងអភិវឌ្ឍបណ្តាញផ្លូវក្នុងតំបន់ពាណិជ្ជកម្មនិងតំបន់ជុំវិញឱ្យបានសមស្រប សម្រាប់បម្រើដល់តំបន់ពាណិជ្ជកម្ម
- លើកទឹកចិត្តឱ្យមានការវិនិយោគដោយបង្កើតជាផ្សារ ហាងលក់ទំនិញ ផ្សាររាត្រី និងមជ្ឈមណ្ឌលពាណិជ្ជកម្ម ធនាគារ ឃ្លាំង សហគ្រាសផ្សេងៗដើម្បីងាយស្រួលក្នុងការដោះដូរទំនិញ បង្កើតការងារ និងលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច
- បង្កើនការរៀបចំកម្មវិធីតាំងពិព័រណ៍ពាណិជ្ជកម្មនិងផ្សព្វផ្សាយផលិតផលគ្រប់ប្រភេទដើម្បីបង្កើនការផលិតនិងជំរុញសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចឱ្យបានខ្លាំងក្លា
- លើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យកែច្នៃផលិតផលក្នុងស្រុកនិងរៀបចំបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មខ្នាតតូច មធ្យម និងធំដើម្បីសមតុល្យក្នុងការនាំចេញនាំចូលទំនិញ។

## ៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ចនិងវប្បធម៌

- ស្តារនិងរៀបចំលម្ហសាធារណៈ ផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនាដល់មនុស្សគ្រប់វ័យរួមមានកុមារ យុវជន ស្ត្រី បុរស មនុស្សវ័យចាស់ និងជនពិការឱ្យទទួលបាននូវសេវាប្រកបដោយសមធម៌
- រៀបចំឱ្យមានផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនពិការ បង្គន់អនាម័យសម្រាប់ជនពិការ និងបរិក្ខារសម្រាប់ជនពិការនៅតាមទីសាធារណៈ អគារសាធារណៈ និងកន្លែងផ្តល់សេវាកម្មផ្សេងៗ
- រៀបចំឱ្យមានសាលារៀន និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់កម្រិតតាមភូមិ ឃុំ ក្នុងស្រុកបរិបូណ៌ស្របតាមអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បន្តជំរុញអនុវត្ត "គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥" សំដៅធានាថា "យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត" សម្រាប់ឆ្លើយតបនឹងតម្រូវការទីផ្សារការងារ
- រៀបចំ កែលម្អ និងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិតមានជាអាទិ៍ប៉ុស្តិ៍សុខភាព កន្លែងសង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ឱសថស្ថាននៅតាមឃុំក្នុងស្រុកបរិបូណ៌ស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល
- បង្កើតមជ្ឈមណ្ឌលថែទាំសុខភាព ថែទាំវេជ្ជសាស្ត្រ និងខ្យល់អាកាសធម្មជាតិ
- ពង្រីកនិងបង្កើតបរិក្ខារកីឡានិងវប្បធម៌ថ្មីដើម្បីឆ្លើយតបនឹងតម្រូវការពេលអនាគត
- ដោះស្រាយសំណង់បណ្តោះអាសន្ននៅលើដីចំណីផ្លូវដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- យកចិត្តទុកដាក់ជួយដល់ប្រជាពលរដ្ឋក្រីក្រនិងជនងាយរងគ្រោះ ជាពិសេសប្រជាជនដែលទទួលរងការគំរាមកំហែងពីគ្រោះធម្មជាតិ
- ជំរុញឱ្យសហគមន៍ទទួលបានការគាំទ្រនិងលើកទឹកចិត្តពីផ្នែកសាធារណៈនិងសង្គមស៊ីវិល

- អភិវឌ្ឍសមត្ថភាពរបស់ប្រជាជននៅជនបទឱ្យមានជំនាញវិជ្ជាជីវៈដែលអាចប្រកបមុខរបរបាន ដើម្បីលើកកម្ពស់កម្រិតជីវភាព
- សិក្សាលទ្ធភាពនិងរៀបចំគម្រោងសម្បទានដីសង្គមកិច្ចសម្រាប់ប្រជាជនក្រីក្រនិងប្រជាជនរស់នៅក្នុងសំណង់បណ្ដោះអាសន្នគ្រប់កន្លែង
- ពង្រឹងសេវាកម្មដោះស្រាយហានិភ័យ សង្គ្រោះបន្ទាន់ សន្តិសុខសណ្ដាប់ធ្នាប់សង្គម និងគ្រោះមហន្តរាយនានាដូចជាគ្រោះអគ្គិភ័យ ទឹកជំនន់ និងបាតុភូតធម្មជាតិផ្សេងៗ។

## ៤.៦-យុទ្ធសាស្ត្រការពារបរិស្ថាននិងគ្រប់គ្រងសំណល់

### ៤.៦.១-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

យោងតាមអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១១ ស្ដីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧ ៤០៦ ហិកតា ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប តំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថានត្រូវបានបែងចែកដូចខាងក្រោមៈ

- តំបន់ព្រៃលិចទឹកបឹងទន្លេសាបត្រូវការពារ មានទំហំ ៨ ៩៣១ ហិកតា ត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១១ ស្ដីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧ ៤០៦ ហិកតា ស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប
- តំបន់វប្បធម៌ប្រវត្តិសាស្ត្រត្រូវការពារ មានប្រាសាទកំពង់ព្រះនៅលើទីទួលក្នុងបរិវេណវត្តកំពង់ព្រះដែលមានប្រាសាទប្រុសនិងប្រាសាទស្រី ស្ថិតក្នុងភូមិកំពង់ព្រះ ឃុំឆ្នុកទ្រូ ស្រុកបរិបូណ៌
- តំបន់សហគមន៍ព្រៃឈើត្រូវការពារ មានចំនួន ៣ កន្លែងនិងមានផ្ទៃដីប្រមាណ ២ ៩៣១ ហិកតា ស្ថិតនៅឃុំត្រពាំងចាន់ ឃុំអញ្ចាញរូង និងឃុំពេជចង្វារ
- ប្រព័ន្ធធារាសាស្ត្រសំខាន់ៗត្រូវការពារ មានចំនួន ២ ធំៗគឺប្រព័ន្ធធារាសាស្ត្រអាចាំងនិងប្រព័ន្ធធារាសាស្ត្រ ២០ ឧសភា ដែលបានផ្ដល់ការស្រោចស្រពដ៏សម្បូរបែបសម្រាប់គាំទ្រដល់វិស័យកសិកម្មក្នុងស្រុកបរិបូណ៌ ក៏ដូចជាខេត្តកំពង់ឆ្នាំង។

### ៤.៦.២-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ការពារនិងថែរក្សាតំបន់ព្រៃលិចទឹកបឹងទន្លេសាបដើម្បីធានាប្រព័ន្ធអេកូឡូស៊ីព្រៃលិចទឹកឱ្យមានផលិតភាពខ្ពស់និងមានសារៈសំខាន់នៅក្នុងអាយុកាលនៃជីវចម្រុះក្នុងបឹងទន្លេសាបដូចជាមានតួនាទីជាកន្លែងពងកូន ឬកន្លែងរកចំណីសម្រាប់ធនធានវារីជាតិនិងត្រី
- ការពារផ្ទៃដីកសិកម្មដោយចៀសវាងការប្ដូរប្រភេទនៃការប្រើប្រាស់ដីនិងលើកទឹកចិត្តការប្រើប្រាស់ដីសរីរាង្គដើម្បីធានានូវទេសភាពស្រស់ស្អាត
- ដោះស្រាយវិវាទដីធ្លីនិងវិវាទនៃការប្រើប្រាស់ដីស្របតាមយន្តការនិងបទដ្ឋានគតិយុត្តជាធរមាន
- អនុវត្តច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងការសាងសង់នៃគម្រោងអភិវឌ្ឍនិងវិនិយោគនានា

- លើកកម្ពស់ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលដល់បរិស្ថាន
- បង្កើតគណៈកម្មាធិការត្រួតពិនិត្យបរិស្ថាននៅថ្នាក់ខេត្តនិងលើកកម្ពស់ចំណេះដឹងរបស់ប្រជាជនអំពីបរិស្ថាន
- រៀបចំឱ្យមានមូលនិធិសម្រាប់ថែទាំបរិស្ថាននិងជំរុញការវិនិយោគរបស់ផ្នែកឯកជននិងរដ្ឋ។

## ៤.៦.៣- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង

- គ្រប់គ្រងសំរាម ជាពិសេសសំណល់រឹងនិងសំណល់វេជ្ជសាស្ត្រ គឺមានសារៈសំខាន់ណាស់ ព្រោះបច្ចុប្បន្ននៅស្រុកបរិបូណ៌ពុំទាន់បានរៀបចំច្បាស់លាស់នៅឡើយ។ ទីតាំងគ្រោងសម្រាប់រៀបចំជារណ្តៅសំណល់រឹង ១ កន្លែងមានផ្ទៃដីប្រមាណ ១២ ហិកតា ស្ថិតនៅក្នុងឃុំពេជចង្វារ
- ពង្រឹងយន្តការគ្រប់គ្រងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងសំណល់រឹង
- រៀបចំមធ្យោបាយនិងបរិក្ខារប្រមូលសំណល់រឹងនិងរៀបចំទីតាំងសម្រាប់ស្តុកសំណល់រឹងបណ្តោះអាសន្នស្របតាមបទដ្ឋានបច្ចេកទេសនិងស្តង់ដាទីក្រុងស្អាត
- អភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសំណល់រឹងនិងបែងចែកសំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញបាន
- អនុវត្តគោលការណ៍គ្រប់គ្រងសំណល់រឹងតាមរយៈការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញនិងការកែច្នៃប្រើប្រាស់ឡើងវិញ
- ដឹកនាំនិងបំផុសការចូលរួមរបស់ប្រជាពលរដ្ឋនិងការវិនិយោគរបស់ផ្នែកឯកជននិងរដ្ឋ។

## ៤.៦.៤- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ

- រៀបចំស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ជាពិសេសនៅតំបន់ឆ្នុកទ្រូដែលមានទឹកកខ្វក់ច្រើន មុននឹងបង្ហូរចូលទៅក្នុងទន្លេឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- រៀបចំនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀងនិងលូទឹកកខ្វក់ឱ្យដាច់ពីគ្នាដោយតភ្ជាប់ទៅនឹងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រនិងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលលូសាធារណៈ
- ណែនាំម្ចាស់សំណង់លំនៅឋាន សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈឱ្យរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់និងអាងបង្គន់អនាម័យឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាននិងអនាម័យដើម្បីធានាបាននិរន្តរភាពតំបន់ទេសចរណ៍ធម្មជាតិ
- ទប់ស្កាត់ការលុបបឹងនិងប្រព័ន្ធផ្លូវទឹកធម្មជាតិក្នុងការយកដីទៅសាងសង់សំណង់ផ្សេងៗ
- កំណត់បទប្បញ្ញត្តិជាក់លាក់ក្នុងការគ្រប់គ្រងសំណល់រាវនិងទប់ស្កាត់ការបំពុលបរិស្ថានបណ្តាលមកពីរោងចក្រ សហគ្រាស សិប្បកម្ម និងអាជីវកម្ម។

## ៤.៧-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ

- លើកកម្ពស់ការការពារតំបន់ព្រៃលិចទឹកបឹងទន្លេសាប ជាពិសេសត្រូវគ្រប់គ្រងឱ្យបានច្បាស់លាស់ការឈូសឆាយដីព្រៃលិចទឹក ការចាក់ដីដើម្បីធានាឱ្យបានតុល្យភាពនៃបឹងទន្លេសាបនិងតំបន់ត្រីពង
- ការពារធនធានធម្មជាតិនិងជីវចម្រុះក្នុងបឹងទន្លេសាបនិងតំបន់ជុំវិញបឹងទន្លេសាបដើម្បីរក្សាបាននូវតុល្យភាពបរិស្ថាននិងប្រព័ន្ធអេកូឡូស៊ី
- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកំពង់ឆ្នាំង (គ.គ.ម.ខ.) គួរបើកកិច្ចប្រជុំនៅរៀងរាល់ ៣ ខែម្តងដោយមានការចូលរួមពីមន្ទីរ អង្គភាពជាសមាជិក គ.គ.ម.ខ. តំណាងដៃគូអភិវឌ្ឍន៍ សាខាកាកបាទក្រហមខេត្តដើម្បីពិភាក្សានិងចែករំលែកព័ត៌មានគ្នាទៅវិញទៅមកពាក់ព័ន្ធនឹងការងារត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននានា។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងខេត្តកំពង់ឆ្នាំងគួរត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចប្រជុំនេះដែរ
- លេខាធិការដ្ឋាន គ.គ.ម.ខ. ដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលកិច្ចសហការរវាង គ.គ.ម.ខ. សាខាកាកបាទក្រហមខេត្តកំពង់ឆ្នាំង ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា
- លេខាធិការដ្ឋាន គ.គ.ម.ខ. ត្រួតពិនិត្យនិងសាកល្បងជាប្រចាំនូវមធ្យោបាយសម្ភារៈមានជាអាទិ៍ កាណូត ទូក ម៉ាស៊ីនភ្លើង
- លេខាធិការដ្ឋាន គ.គ.ម.ខ. ត្រូវផ្សព្វផ្សាយនិងណែនាំដល់សមាជិក គ.គ.ម.ខ. រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានាអំពីគំរូរបាយការណ៍ដែលត្រូវរាយការណ៍មកលេខាធិការដ្ឋានក្នុងពេលមានគ្រោះអាសន្ន
- មន្ទីរធនធានទឹកនិងឧតុនិយមខេត្តកំពង់ឆ្នាំងសហការជាមួយមន្ទីរព័ត៌មានខេត្តកំពង់ឆ្នាំងតាមដាននិងជូនដំណឹងដល់ប្រជាជនជាប្រចាំអំពីស្ថានភាពអាកាសធាតុនិងកម្ពស់ទឹក
- លេខាធិការដ្ឋាន គ.គ.ម.ខ. សហការជាមួយមន្ត្រីទទួលបន្ទុករដ្ឋបាលខេត្តតាមដានព័ត៌មានផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយជាតិ អន្តរជាតិ បណ្តាញទំនាក់ទំនងសង្គម គេហទំព័ររបស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល ឬប្រព័ន្ធតាមដានមុខសញ្ញាគ្រោះមហន្តរាយអន្តរជាតិ ឬតំបន់ដើម្បីអាចដឹងជាមុនអំពីមុខសញ្ញាដែលអាចនឹងមានឥទ្ធិពលចំពោះខេត្តនិងអាចជូនដំណឹងដល់អ្នកពាក់ព័ន្ធនានាដើម្បីផ្តល់ដំណឹងដល់ប្រជាជនបានទាន់ពេលវេលា
- មន្ទីរ អង្គភាព និងកងកម្លាំងប្រដាប់អាវុធត្រៀមមធ្យោបាយ ធនធាន សម្ភារៈសមស្របដើម្បីជួយសង្គ្រោះប្រជាជនក្នុងពេលមានគ្រោះអាសន្ន
- ស្រុក ឃុំត្រួតពិនិត្យស្ថានភាពទីទួលសុវត្ថិភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីត្រៀមជម្លៀសប្រជាជនក្នុងពេលមានគ្រោះអាសន្ន
- សិក្សាពីបម្រែបម្រួលអាកាសធាតុដែលធ្វើឱ្យកើនឡើងកម្តៅនិងធ្វើឱ្យរបបទឹកនិងកម្ពស់ទឹកភ្លៀងមិនទៀងទាត់នាំឱ្យប៉ះពាល់ដល់ប្រជាជននិងការអភិវឌ្ឍលើគ្រប់វិស័យ
- រាល់គម្រោងអភិវឌ្ឍចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមជាមុន
- បន្តអនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

### ៤.៨-យុទ្ធសាស្ត្រពង្រឹងអភិបាលកិច្ចល្អ គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន

អភិបាលកិច្ចល្អ គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋានគឺជាកត្តាសំខាន់ចាំបាច់និងជាស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច អភិវឌ្ឍស្រុកបរិបូណ៌ និងការពារបរិស្ថានដោយចាំបាច់ត្រូវ៖

- សម្របសម្រួលស្ថាប័នពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានអំពីគម្រោងដែលត្រូវអនុវត្ត និងគម្រោងដែលត្រូវស្នើឡើងក្នុងស្រុក និងក្នុងខេត្ត
- បណ្តុះបណ្តាលធនធានមនុស្សទាំងនៅថ្នាក់ខេត្តនិងថ្នាក់ស្រុក ជាពិសេសការគ្រប់គ្រង ការអភិវឌ្ឍ និងការត្រួតពិនិត្យគម្រោងសាធារណៈ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ។ល។
- អនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រើប្រាស់ដីសាធារណៈ ការផ្តល់លិខិតអនុញ្ញាតសាងសង់ ការចុះបញ្ជីយានយន្ត ការបូមទឹកក្រោមដីរបស់ឯកជន និងការគ្រប់គ្រងបរិស្ថាន
- ពង្រឹងហិរញ្ញវត្ថុនៅមូលដ្ឋានតាមរយៈការប្រមូលចំណូលនៅមូលដ្ឋាន ការបែងចែកចំណូលរដ្ឋពីវិស័យទេសចរណ៍និងប្រភពផ្សេងៗទៀតដល់រដ្ឋបាលមូលដ្ឋានសម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈ ជាពិសេសសម្រាប់ការជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងការលើកកម្ពស់សោភ័ណភាពនិងបរិស្ថាននៅក្នុងស្រុក។

## ៥-ផែនការសកម្មភាព

ផ្អែកតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជានិងប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ រដ្ឋបាលស្រុកបរិបូណ៌ និងរដ្ឋបាលខេត្តកំពង់ឆ្នាំង ព្រមទាំងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តផែនការសកម្មភាពសំខាន់ៗដូចតទៅ៖

### ៥.១-ការរៀបចំបញ្ញត្តិនគរូបនីយកម្ម

ដើម្បីសម្រេចនូវគោលបំណងនេះ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវមានយុទ្ធសាស្ត្ររបស់ខ្លួនឱ្យបានច្បាស់លាស់ដោយចាំបាច់ត្រូវកំណត់ប្លង់អភិវឌ្ឍលម្អិតតាមតំបន់អភិវឌ្ឍនីមួយៗរួមមាន៖

- រៀបចំផែនទីកំណត់កម្ពស់អគារក្នុងស្រុក ជាពិសេសនៅតាមបណ្តោយកំណាត់ផ្លូវជាតិលេខ ៥ និងតាមបណ្តោយផ្លូវសំខាន់ៗ
- រៀបចំផែនទីកំណត់តំបន់អភិវឌ្ឍជាអាទិភាព
- រៀបចំប្លង់តម្រង់ទិសនៃការអភិវឌ្ឍ
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍដី ការសាងសង់ និងប្លង់លម្អិតនគរូបនីយកម្ម ជាពិសេសតំបន់ផ្សារពន្លៃនិងតំបន់ទីប្រជុំជន។

### ៥.២-ការផ្សព្វផ្សាយ

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មស្រុកបរិបូណ៌ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពង់ឆ្នាំងត្រូវផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ដល់មន្ត្រីជំនាញ វិនិយោគិន និងប្រជាពលរដ្ឋតាមរយៈកិច្ចប្រជុំ សិក្ខាសាលា គេហទំព័រ ឬតាមបណ្តាញទំនាក់ទំនងសង្គម។ល។

### ៥.៣-ការអនុវត្តគម្រោងតាមវិស័យ

គម្រោងតាមវិស័យសំខាន់ៗដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍរួមមាន៖

#### ៥.៣.១-ការអភិវឌ្ឍស្រុកបរិបូណ៌

- កំណត់ព្រំប្រទល់រដ្ឋបាលស្រុក ឃុំ ភូមិឱ្យបានច្បាស់លាស់
- កំណត់តំបន់ទីប្រជុំជន ការអភិវឌ្ឍនគរូបនីយកម្ម និងតំបន់ជនបទ
- ដាក់លេខផ្ទះនិងឈ្មោះឬលេខផ្លូវដើម្បីងាយស្រួលក្នុងការគ្រប់គ្រង
- កែលម្អនិងស្ដារសោភ័ណភាពនិងហេដ្ឋារចនាសម្ព័ន្ធតំបន់ទីប្រជុំជន
- កសាងសមត្ថភាពធ្វើផែនការនៅថ្នាក់ស្រុក
- រៀបចំអភិវឌ្ឍដីឡូត៍ដែលមិនទាន់បានប្រើប្រាស់ឱ្យធ្វើការអភិវឌ្ឍនិងការប្រើប្រាស់ឱ្យបានចំទិសដៅនិងមុខងារ
- រៀបចំកំណត់ឆ្លាតម្លាតអគារឱ្យស្របទៅតាមប្លង់នគរូបនីយបញ្ញត្តិ
- ការពារនិងថែរក្សារចនាបថខ្មែរនិងឯកសណ្ឋានភាពនៃសំណង់
- រៀបចំប្លង់ស្ថាបត្យកម្មងាយៗនិងសាមញ្ញបែបខ្មែរធ្វើជាគំរូដើម្បីផ្សព្វផ្សាយជូនប្រជាពលរដ្ឋសម្រាប់សាងសង់លំនៅឋាននៅមូលដ្ឋាន
- បន្តនិងបង្កើនល្បឿននៃការចុះបញ្ជីដីធ្លីឱ្យបានចប់សព្វគ្រប់
- រៀបចំលំនៅឋានឱ្យមានសណ្ដាប់ធ្នាប់ស្របតាមគោលនយោបាយជាតិស្ដីពីលំនៅឋាន។

#### ៥.៣.២-ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន

- កែលម្អប្រព័ន្ធដឹកជញ្ជូននៅជនបទតាមរយៈការថែទាំផ្លូវដែលមានស្រាប់និងបង្កើនលទ្ធភាពទៅដល់តំបន់ជនបទ
- រៀបចំសារពើភ័ណ្ឌផ្លូវជនបទនិងធ្វើផែនទីផ្លូវជនបទឱ្យមានស្ថិរភាពនិងធ្វើឱ្យប្រសើរឡើងជីវភាពរស់នៅរបស់ប្រជាជនដោយថែរក្សាផ្លូវជនបទដែលមានស្រាប់និងស្ដារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននៅតាមជនបទ
- ស្ថាបនាផ្លូវដឹកជញ្ជូនថ្មីមួយខ្សែវាងទីប្រជុំជន មានទំហំ ៥០ ម៉ែត្រ និងប្រវែង ១៩ គីឡូម៉ែត្រចាប់ពីឃុំផ្សារទៅដល់អន្សាចំបក់ ខេត្តពោធិ៍សាត់ដើម្បីបញ្ចៀសចរាចរណ៍ក្នុងតំបន់ទីប្រជុំជនពន្លៃ ក៏ដូចជាកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍
- ស្ថាបនាផ្លូវដីក្រាលគ្រួសក្រហម ជួសជុលផ្លូវ និងធ្វើលូកាត់ផ្លូវ
- កសាងកំពង់ផែដ៏ស្រស់ស្អាតនិងស្ដារផ្លូវទឹកដើម្បីឱ្យទូកទេសចរណ៍ ឬនាវាទេសចរណ៍ ឬនាវាដឹកជញ្ជូនអាចចូលចតបាន នៅឃុំផ្ទុកទ្រ
- កសាងចំណតទូកនេសាទដើម្បីគ្រប់គ្រងការនេសាទនៅតំបន់ផ្ទុកទ្រនិងរក្សាសណ្ដាប់ធ្នាប់របៀបរៀបរយនៅបឹងទន្លេសាប។

### ៥.៣.៣- ការផ្គត់ផ្គង់ទឹកស្អាតនិងធនធានទឹក

- លើកទឹកចិត្តឱ្យមានការវិនិយោគផ្គត់ផ្គង់ទឹកស្អាតនៅក្នុងស្រុកបរិបូណ៌
- រៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងស្រុកដោយប្រើប្រាស់ប្រភពទឹកពីប្រព័ន្ធធារាសាស្ត្រអាចាំង ឬភ្ជាប់ពីបណ្តាញទឹកស្អាតរបស់ខេត្តកំពង់ឆ្នាំង ឬទាញយកទឹកពីបឹងទន្លេសាប
- រៀបចំបទប្បញ្ញត្តិនិងចាត់វិធានការផ្សេងៗក្នុងការការពារប្រភពផ្គត់ផ្គង់ទឹក។

### ៥.៣.៤- ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ និងព័ត៌មានវិទ្យា

- ពង្រីកបន្ថែមបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិ
- ពង្រីកតំបន់ទទួលបានការផ្គត់ផ្គង់ប្រព័ន្ធទូរគមនាគមន៍និងប្រព័ន្ធព័ត៌មានវិទ្យាឱ្យបានគ្របដណ្តប់ទូទាំងស្រុក
- តាមដានប្រសិទ្ធភាព គុណភាព និងតម្លៃនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីនិងទូរគមនាគមន៍។

### ៥.៣.៥- ការអភិវឌ្ឍកសិកម្មនិងផ្សព្វផ្សាយផលិតផលក្នុងស្រុក

- ថែរក្សានិងការពារដីកសិកម្មឱ្យមានប្រសិទ្ធភាពនិងចីរភាពដើម្បីធានាសន្តិសុខស្បៀង
- កែលម្អនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់កសិកម្មមានជាអាទិ៍ប្រព័ន្ធធារាសាស្ត្រ អាងស្តុកទឹក ផ្លូវដឹកជញ្ជូន
- បណ្តុះបណ្តាលដល់ប្រជាកសិករអំពីផលប្រយោជន៍និងវិធីសាស្ត្រក្នុងការប្រើប្រាស់ជីសរីរាង្គ
- អនុវត្តដំណើរការសហគមន៍មួយផលិតផលមួយ
- ថែរក្សានិងពង្រីកទីផ្សារផលិតផលកសិកម្ម
- ផ្តួចផ្តើមអភិវឌ្ឍកសិកម្មបែបទំនើបនិងជំរុញការប្រើប្រាស់បច្ចេកវិទ្យាឆ្លាតវៃនិងឌីជីថល។

### ៥.៣.៦- ការអភិវឌ្ឍទេសចរណ៍

- ត្រួតពិនិត្យគុណភាពនិងអនាម័យចំណីអាហារនិងការស្នាក់នៅស្របតាមបទដ្ឋានអនាម័យ
- បណ្តុះបណ្តាលបុគ្គលិកដែលបម្រើសេវាកម្មទេសចរណ៍ បដិសណ្ឋារកិច្ច មគ្គុទេសក៍ទេសចរណ៍ និងអ្នកគ្រប់គ្រងសេវាកម្មឱ្យមានជំនាញវិជ្ជាជីវៈច្បាស់លាស់នឹងឈានដល់កម្រិតស្តង់ដាជាតិនិងអន្តរជាតិ
- ផ្សព្វផ្សាយទេសចរណ៍ដ៏សម្បូរបែបនិងប្រកបដោយភាពទាក់ទាញតាមរយៈប្រព័ន្ធផ្សព្វផ្សាយ គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម។ល។
- កែលម្អនិងរៀបចំផ្សារ កន្លែងលក់វត្ថុអនុស្សាវរីយ៍ កន្លែងផ្តល់សេវាកម្ម និងព័ត៌មានទេសចរណ៍
- បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងសាធារណៈស្រុកបរិបូណ៌លើវិស័យទេសចរណ៍
- អភិវឌ្ឍនិងលើកកម្ពស់ទេសចរណ៍តាមភូមិនិងទេសចរណ៍ធម្មជាតិ
- សិក្សាលម្អិតពីលទ្ធភាពទទួលភ្ញៀវទេសចរនិងការគ្រប់គ្រងរមណីយដ្ឋាន
- បោះពុម្ពផែនទីគោលដៅទេសចរណ៍និងបោះពុម្ពសៀវភៅផ្តត់ទេសចរណ៍ជាភាសាខ្មែរនិងភាសាបរទេសចាំបាច់និងធ្វើផ្លាកសញ្ញានិងផែនទីចង្អុលបង្ហាញទីតាំងតំបន់ទេសចរណ៍។

### ៥.៣.៧- ការការពារបរិស្ថាន

- ពង្រឹងសមត្ថភាពស្ថាប័ន
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- ប្រមូលកម្រៃរួមពីសេវាកម្មសាធារណៈ
- គ្រប់គ្រងប្រេងឥន្ធនៈចាក់តាមទូកនិងនាវាកុំឱ្យមានការលេចធ្លាយចូលក្នុងទឹក
- សិក្សាប្លង់មេគ្រប់គ្រងគ្រោះមហន្តរាយដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន កំណត់និងកសាងប្រព័ន្ធប្រឡាយរំដោះទឹកនិងអាងស្តុកទឹកដើម្បីបញ្ចៀសការជន់លិចទីប្រជុំជន
- ផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងអំពីការការពារបរិស្ថាននិងការត្រៀមខ្លួនឆ្លើយតបនឹងបម្រែបម្រួលអាកាសធាតុដើម្បីទាក់ទាញការចូលរួមរបស់ប្រជាជននិងភាគីពាក់ព័ន្ធ
- លើកទឹកចិត្តនិងទាក់ទាញការវិនិយោគរបស់ផ្នែកឯកជនក្នុងការកសាងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបរិស្ថាននិងភាពបន្សុំនឹងការប្រែប្រួលអាកាសធាតុ។

### ៥.៣.៨- ការគ្រប់គ្រងសំណល់រឹង

- កសាងហេដ្ឋារចនាសម្ព័ន្ធនិងអភិវឌ្ឍទីលានទុកដាក់សំណល់រឹងអនាម័យដែលមានផ្ទៃដីប្រមាណ ១២ ហិកតា ស្ថិតនៅក្នុងឃុំពេជចង្វារស្របតាមបទដ្ឋានបច្ចេកទេសបរិស្ថាន
- សហការជាមួយដៃគូអភិវឌ្ឍន៍ ឬផ្នែកឯកជនដើម្បីប្រមូលសំណល់រឹង
- អប់រំនិងផ្សព្វផ្សាយដល់ប្រជាជនអំពីគោលការណ៍គ្រប់គ្រងសំណល់រឹងតាមរយៈការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញ
- តាមដាននិងវាយតម្លៃលើការប្រមូលនិងទុកដាក់សំណល់រឹងរបស់ដៃគូអភិវឌ្ឍន៍ ឬផ្នែកឯកជន
- តាមដានប្រសិទ្ធភាព គុណភាព និងតម្លៃសេវាប្រមូលសំណល់រឹង
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជនអំពីវិធានការគ្រប់គ្រងសំណល់រឹង។

### ៥.៣.៩-ការគ្រប់គ្រងសំណល់រាវនិងប្រព័ន្ធបង្ហូរទឹកភ្លៀង

- កសាងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់នៅតំបន់ឆ្នុកទ្រូ ផ្នែកខាងក្រោយផ្សារពន្លៃឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀងនិងលូទឹកកខ្វក់ឱ្យដាច់ពីគ្នាដោយតភ្ជាប់ទៅនឹងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រនិងត្រូវចម្រោះទឹកកខ្វក់ឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យមុននឹងបង្ហូរចូលលូសាធារណៈ
- ណែនាំម្ចាស់សំណង់លំនៅឋាន សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈឱ្យរៀបចំអាងប្រព្រឹត្តិកម្មទឹកកខ្វក់និងអាងបង្គន់អនាម័យឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាននិងអនាម័យដើម្បីធានាបាននិរន្តរភាពតំបន់ទេសចរណ៍ធម្មជាតិ
- ទប់ស្កាត់ការលុបបឹងនិងប្រព័ន្ធផ្លូវទឹកធម្មជាតិក្នុងការយកដីទៅសាងសង់សំណង់ផ្សេងៗ។

### ៥.៣.១០-ការបង្ការទប់ស្កាត់គ្រោះមហន្តរាយ

- លើកកម្ពស់ការការពារតំបន់ព្រៃលិចទឹកបឹងទន្លេសាប ជាពិសេសត្រូវគ្រប់គ្រងឱ្យបានច្បាស់លាស់ការឈូសឆាយដីព្រៃលិចទឹក ការចាក់ដីដើម្បីធានាឱ្យបានតុល្យភាពនៃបឹងទន្លេសាបនិងតំបន់ត្រីពង
- ការពារធនធានធម្មជាតិនិងជីវចម្រុះក្នុងបឹងទន្លេសាបនិងតំបន់ជុំវិញបឹងទន្លេសាបដើម្បីរក្សាបាននូវតុល្យភាពបរិស្ថាននិងប្រព័ន្ធអេកូឡូស៊ី
- គ.គ.ម.ខ. បើកកិច្ចប្រជុំនៅរៀងរាល់ ៣ ខែម្តងដោយមានការចូលរួមពីមន្ទីរ អង្គភាពជាសមាជិក គ.គ.ម.ខ. តំណាងដៃគូអភិវឌ្ឍន៍ សាខាកាកបាទក្រហមខេត្តដើម្បីពិភាក្សានិងចែករំលែកព័ត៌មានគ្នាទៅវិញទៅមកពាក់ព័ន្ធនឹងការងារត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ននានា។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងខេត្តកំពង់ឆ្នាំងគួរត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចប្រជុំនេះដែរ
- លេខាធិការដ្ឋាន គ.គ.ម.ខ. ត្រួតពិនិត្យនិងសាកល្បងជាប្រចាំនូវមធ្យោបាយសម្ភារៈមានជាអាទិ៍ កាណូត ទូក ម៉ាស៊ីនភ្លើង
- លេខាធិការដ្ឋាន គ.គ.ម.ខ. ត្រូវផ្សព្វផ្សាយនិងណែនាំដល់សមាជិក គ.គ.ម.ខ. រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធនានាអំពីគំរូរបាយការណ៍ដែលត្រូវរាយការណ៍មកលេខាធិការដ្ឋានក្នុងពេលមានគ្រោះអាសន្ន។

## ៥.៤-ការអនុវត្តគម្រោងរយៈពេលខ្លី មធ្យម និងវែង

ផែនការសកម្មភាពចែកចេញជា ៣ ដំណាក់កាល គឺសម្រាប់អនុវត្តគម្រោងរយៈពេលខ្លី ឬគម្រោងអាទិភាព រយៈពេលមធ្យម និងរយៈពេលវែងដូចខាងក្រោម៖

### ៥.៤.១-ការអនុវត្តគម្រោងរយៈពេលខ្លី ឬគម្រោងអាទិភាព

- រៀបចំបញ្ញត្តិនៃការប្រើប្រាស់ដីតាមតំបន់នីមួយៗដើម្បីជាមូលដ្ឋានសម្រាប់តម្រង់ទិសនិងគ្រប់គ្រងដំណើរការនៃការអភិវឌ្ឍស្របតាមចក្ខុវិស័យរបស់ស្រុក
- រៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជាផ្លូវ ប្រព័ន្ធលូ ទឹកស្អាត និងការកែសម្រួលសណ្តាប់ធ្នាប់ផ្សារនិងទីសាធារណៈសំខាន់ៗមួយចំនួនដូចជាសួនច្បារ ចំណតរថយន្ត។ល។
- អភិវឌ្ឍតំបន់លំនៅឋានក្នុងទីប្រជុំជនឱ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ និងមានជាសុកភាពស្របតាមគោលនយោបាយជាតិស្តីពីលំនៅឋាន
- កែលម្អនិងរៀបចំតម្រង់ទិសការតាំងទីលំនៅរបស់ប្រជាពលរដ្ឋតាមដងផ្លូវដែលមានស្រាប់និងផ្លូវសាងសង់ថ្មីឱ្យមានសណ្តាប់ធ្នាប់និងមានលក្ខណៈប្រមូលផ្តុំដើម្បីងាយស្រួលក្នុងការគ្រប់គ្រងនិងការផ្តល់សេវាផ្សេងៗ។

### ៥.៤.២-ការអនុវត្តគម្រោងរយៈពេលមធ្យម

- ធ្វើការផ្សព្វផ្សាយតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រនិងវប្បធម៌ប្រាសាទកំពង់ព្រះនិងតំបន់ទេសចរណ៍តាមបណ្តោយស្ទឹងនៅតំបន់ខ្សាច់បីជាន់ដើម្បីទាក់ទាញយកផលចំណេញផ្នែកទេសចរណ៍នាពេលដ៏ខ្លីនិងបំផុសនូវតំបន់ទេសចរណ៍ថ្មីមួយចំនួនដូចជាព្រៃលិចទឹក ចំការដំណាំហូបផ្លែជាដើម

- បំផុសចលនាភូមិមួយផលិតផលមួយក្នុងការជំរុញនូវការដាំដុះ សិប្បកម្ម ឬវត្ថុកែច្នៃប្រចាំតំបន់
- បង្កើតផ្លូវថ្មី ១ ខ្សែក្នុងស្រុកដើម្បីបញ្ចៀសចរាចរណ៍និងសម្រួលដល់ការធ្វើដំណើរនិងដឹកជញ្ជូន
- ភ្ជាប់ផ្លូវសំខាន់ៗក្នុងស្រុកសម្រាប់ភ្ជាប់ទំនាក់ទំនងពីឃុំមួយទៅឃុំមួយនិងពីតំបន់មួយទៅតំបន់ជុំវិញ
- រៀបចំនិងកែលម្អប្រព័ន្ធធារាសាស្ត្រឱ្យបានគ្រប់គ្រាន់ដើម្បីបម្រើដល់ការអភិវឌ្ឍកសិកម្មរួមមានស្រូវ ដំណាំ នេសាទ និងចិញ្ចឹមសត្វដែលជាមូលដ្ឋានដ៏រឹងមាំសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច
- លើកគម្រោងកែលម្អនិងសាងសង់បន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធគាំទ្រសង្គមរួមមានសាលារៀន មណ្ឌលសុខភាព និងទីតាំងផ្តល់សេវាសាធារណៈផ្សេងៗទៀត
- រៀបចំរណ្តៅចាក់សំរាមនិងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ឱ្យបានសមស្របតាមលក្ខណៈបច្ចេកទេស។

### ៥.៤.៣- ការអនុវត្តគម្រោងរយៈពេលវែង

- បង្កើតទីផ្សារសេដ្ឋកិច្ចដោយខ្លួនឯងតាមរយៈផលិតផលកសិកម្ម សិប្បកម្ម និងនេសាទដើម្បីបង្កើនប្រាក់ចំណូលដល់ស្រុក
- រៀបចំទុកជាមុននូវតំបន់លំនៅឋានសម្រាប់កំណើនប្រជាជន ក៏ដូចជាការបម្លាស់ទី ឬការអភិវឌ្ឍនៅនឹងកន្លែងចំពោះលំនៅឋានប្រជាពលរដ្ឋមួយចំនួនដែលរស់នៅមិនរៀបរយ
- បង្កើតទីផ្សារលក់ផលិតផលនៅឃុំពន្លៃដើម្បីទាញយកផលប្រយោជន៍ឱ្យបានកាន់តែច្រើន
- លើកទឹកចិត្តក្នុងការបង្កើតរោងចក្រឧស្សាហកម្មសម្រាប់កែច្នៃផលិតផលកសិកម្ម នេសាទ និងសិប្បកម្មដែលជាចំណូលដ៏សំខាន់និងជាប្រភពការងារសម្រាប់ប្រជាពលរដ្ឋនៅក្នុងស្រុក
- ពង្រឹងសន្តិសុខសង្គមឱ្យបានល្អសម្រាប់ទាក់ទាញអ្នកវិនិយោគមកចូលរួមអភិវឌ្ឍនិងបង្កើតការងារជូនប្រជាពលរដ្ឋនៅមូលដ្ឋាន
- ពង្រឹងនិងពង្រីកសក្តានុពលផ្នែកសេដ្ឋកិច្ចតំបន់ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការរបស់ប្រជាជន
- ទាញយកផលប្រយោជន៍ពីភ្ញៀវទេសចរដោយពង្រឹងតំបន់ទេសចរណ៍ដូចជាភ្នុកទ្រូ និងប្រាសាទកំពង់ព្រះផ្សារភ្ជាប់នឹងព្រៃលិចទឹកដែលជាតំបន់អភិរក្ស
- បើកចំហនូវច្រកទំនាក់ទំនងតំបន់ជុំវិញឱ្យបានច្រើនតាមរយៈផ្លូវគោក ផ្លូវទឹក។

## ៦-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌មានជាអាទិ៍ៈ

- ថវិកាជាតិ
- ថវិកាអភិវឌ្ឍន៍និងវិនិយោគដោយឯកជន
- ថវិកាវិនិយោគរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

### ៧.១-យន្តការ

យន្តការថ្នាក់ជាតិដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ ចក្ខុវិស័យឆ្នាំ ២០៣០ មាន៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួង ស្ថាប័នតាមវិស័យរបស់រដ្ឋ។

យន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ ចក្ខុវិស័យឆ្នាំ ២០៣០ មាន៖ រដ្ឋបាលខេត្តកំពង់ឆ្នាំង គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពង់ឆ្នាំង រដ្ឋបាលស្រុកបរិបូណ៌ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មស្រុកបរិបូណ៌ មន្ទីរ អង្គភាពជុំវិញខេត្ត និងអាជ្ញាធរឃុំនិងភូមិ។

### ៧.២-ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌សម្រាប់ចក្ខុវិស័យឆ្នាំ ២០៣០ ត្រូវអនុវត្តដោយផ្អែកទៅលើច្បាប់និងក្របខណ្ឌគតិយុត្តមានជាអាទិ៍ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គោលនយោបាយជាតិស្តីពីលំនៅឋាន គោលនយោបាយជាតិស្តីពីដីធ្លី គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីការកំណត់ដែនព្រៃលិចទឹកបឹងទន្លេសាប និងសេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

### ៧.៣-ភារកិច្ច នីតិវិធី និងគោលការណ៍

រដ្ឋបាលស្រុកបរិបូណ៌ដោយមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកបរិបូណ៌ជាសេនាធិការមានភារកិច្ច៖

- ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិតសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើត្រូវកំណត់នូវគោលបំណង គោលដៅ សកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗសម្រាប់ការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ ផែនការវិនិយោគ ៣ ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មថ្នាក់ស្រុក និងឃុំ
- ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ក្នុងរយៈពេល ៥ ឆ្នាំម្តងស្របតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់ឬតាមពេលវេលានិងតម្រូវការចាំបាច់ជាក់ស្តែងសំដៅបម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ

- ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំនៃការអនុវត្តប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពង់ឆ្នាំង រដ្ឋបាលខេត្តកំពង់ឆ្នាំង ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិដើម្បីធ្វើការបូកសរុបនិងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

គោលការណ៍នៃការត្រួតពិនិត្យនិងវាយតម្លៃត្រូវផ្អែកលើសូចនាករនៃការរៀបចំដែនដីនិងនគរូបនីយកម្ម និងសូចនាករតាមវិស័យដែលជាកត្តាគូសបញ្ជាក់អំពីប្រសិទ្ធភាពនៃប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមប្រកបដោយចីរភាព។

## ៨-សេចក្តីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យតាមរយៈការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ត្រូវបានរៀបចំឡើងនិងសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គឺជាឧបករណ៍គតិយុត្តគោលសម្រាប់ការអនុវត្តនិងសម្របសម្រួលស្ថាប័នពាក់ព័ន្ធតាមវិស័យដ៏មានសារៈសំខាន់ដើម្បីធានាសម្រេចបានចក្ខុវិស័យដល់ឆ្នាំ ២០៣០ គឺ "ជាស្រុកគំរូក្នុងតំបន់បឹងទន្លេសាបលើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថានល្អប្រសើរប្រកបដោយចីរភាព តុល្យភាព និងបរិយាបន្ន" តាមរយៈការជំរុញ៖ ១)ការអភិវឌ្ឍតំបន់ទីប្រជុំជននិងតំបន់ជនបទប្រកបដោយសោភ័ណភាព អត្តសញ្ញាណ វប្បធម៌ និងធម្មជាតិល្អប្រសើរក្នុងភូមិសាស្ត្រតំបន់បឹងទន្លេសាប ២)ការអភិវឌ្ឍកសិកម្មនិងជលផលប្រកបដោយចំណេះដឹង ការច្នៃប្រឌិត និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ៣)ការអភិវឌ្ឍពាណិជ្ជកម្ម សេវាកម្ម ឧស្សាហកម្មសិប្បកម្មកែច្នៃនិងវិចខ្ចប់ផលិតផលកសិកម្មនិងជលផល សម្រាប់ការផ្គត់ផ្គង់ក្នុងស្រុកនិងការនាំចេញ ៤)ការអភិវឌ្ឍទេសចរណ៍វប្បធម៌និងធម្មជាតិតាមរយៈការលើកកម្ពស់ការរៀបចំនិងអភិរក្សតំបន់វប្បធម៌ប្រាសាទកំពង់ព្រះ តំបន់ធនធានធម្មជាតិអាងបឹងទន្លេសាបនិងតំបន់ជុំវិញ ស្ទឹងបរិបូណ៌ និងតំបន់ទេសភាពធម្មជាតិ ភ្នំនាងកង្រី និង ៥)ការលើកកម្ពស់អភិបាលកិច្ចល្អ ការថែរក្សាអត្តសញ្ញាណវប្បធម៌ជាតិ កិច្ចការពារធនធានធម្មជាតិ បរិស្ថាន និងការអភិវឌ្ឍបៃតង ដើម្បីរួមចំណែកអភិវឌ្ឍនិងប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

ថ្ងៃ ពុធ ១២ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**អនុសាសន៍**

ប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌បានផ្តល់អនុសាសន៍ដល់រដ្ឋបាលស្រុកបរិបូណ៌ មន្ទីរអង្គភាព រដ្ឋបាលខេត្តកំពង់ឆ្នាំង និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ដូចខាងក្រោមៈ

១) គ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ចនិងភាគីពាក់ព័ន្ធជួយគាំទ្រដល់រដ្ឋបាលស្រុកបរិបូណ៌ក្នុងការអនុវត្តប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ដែលបានសម្រេចដាក់ឱ្យប្រើប្រាស់រួចដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន។

២) កំណត់ឱ្យបានច្បាស់លាស់នូវបញ្ហានិងបរិស្ថានស្រុកបរិបូណ៌ដើម្បីទាក់ទាញលំហូរភ្ញៀវទេសចរនិងវិនិយោគិនចូលមកក្នុងស្រុកបរិបូណ៌សំដៅប្រកួតប្រជែងជាមួយតំបន់ទេសចរណ៍ផ្សេងៗទៀតនៅក្នុងខេត្តកំពង់ឆ្នាំងនិងខេត្តផ្សេងៗទៀត។

៣) ផ្គត់ផ្គង់ទឹកស្អាតសម្រាប់ភ្ញៀវទេសចរនិងប្រជាជន និងការស្រោចស្រពដីកសិកម្មដែលជាខ្សែក្រវាត់បៃតងរបស់ស្រុក។

៤) សម្របសម្រួលការធ្វើផែនការប្រើប្រាស់ដីដោយមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋានដើម្បីឱ្យការគ្រប់គ្រងដីធ្លីអនុវត្តមានប្រសិទ្ធភាព។

៥) ពិនិត្យវាយតម្លៃនិងកែលម្អប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌រៀងរាល់ ៥ ឆ្នាំម្តងដើម្បីឆ្លើយតបទៅនឹងកាលៈទេសៈប្រែប្រួលនិងតម្រូវការសេដ្ឋកិច្ចសង្គមជាក់ស្តែង។

៦) កសាងសមត្ថភាពមន្ត្រីជំនាញនៅថ្នាក់ស្រុក ថ្នាក់ខេត្ត និងលើកកម្ពស់ការចែករំលែកព័ត៌មានអំពីគម្រោងអភិវឌ្ឍនានារវាងមន្ទីរអង្គភាពជំនាញនិងសមត្ថកិច្ចពាក់ព័ន្ធនៅក្នុងខេត្តតាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពង់ឆ្នាំង។

៧) លើកកម្ពស់សមត្ថភាពបច្ចេកទេសសម្រាប់ការត្រួតពិនិត្យនិងថែរក្សាបរិស្ថានឱ្យមានប្រសិទ្ធភាពដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងខេត្ត។ រដ្ឋបាលខេត្តកំពង់ឆ្នាំងត្រូវរៀបចំកញ្ចប់ថវិកាសម្រាប់អាជ្ញាធរស្រុកបរិបូណ៌អនុវត្តផែនការជួសជុលនិងថែទាំបរិក្ខារសាធារណៈដូចជាផ្លូវ សួនច្បារ សំណល់រឹងនិងរាវ និងប្រព័ន្ធបង្ហូរទឹកភ្លៀងនិងទឹកកខ្វក់។ល។

**សន្ទានុក្រម**

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូចស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។

**នគរូបនីយកម្ម** សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំងតំបន់ទទួលឥទ្ធិពលក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភ័ណភាព សមធម៌ និងសមាហរណកម្ម។

**ផែនការរៀបចំដែនដីថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត** សំដៅដល់ផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រ តម្រង់ទិសការប្រើប្រាស់ដីនិងការអភិវឌ្ឍផ្នែករូបវន្តដោយផ្អែកលើសក្តានុពលនៃភូមិសាស្ត្រនិងតំបន់នីមួយៗក្នុងក្របខណ្ឌថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត។

**ប្លង់គោលប្រើប្រាស់ដី ឬប្លង់គោល** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុបសម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី (ប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្តាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុង ព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍនិងអភិរក្សទីក្រុងទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ញានៃការប្រើប្រាស់ដីជាក់ស្តែង ការសាងសង់ ការអភិវឌ្ឍដី និងការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្តាញគមនាគមន៍និងការធ្វើសមាហរណកម្ម។ ផែនការប្រើប្រាស់ដីគឺជាផែនការដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់វិលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុង ឬជាគម្រោងអភិវឌ្ឍទីក្រុងដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបវន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយ ឬច្រើនទីក្រុងដែលរួមមានការបង្ហាញអំពីការរៀបចំការរចនាទម្រង់ រូបរាង និងសោភ័ណភាពនៃរចនាសម្ព័ន្ធរូបវន្តសម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្មត្រូវគោរពតាមផែនការប្រើប្រាស់ដី។

ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ សំដៅដល់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជនដោយប៉ាន់ប្រមាណពីសក្តានុពលដីនិងធនធានទឹក លទ្ធភាពផ្សេងៗក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គមកិច្ចដើម្បីធ្វើការជ្រើសរើសនូវជម្រើសសមស្របក្នុងការប្រើប្រាស់ដី។

ប្រភេទដីអាចសាងសង់បាន សំដៅដល់ប្រភេទដីដែលជំរុញឱ្យមានការអភិវឌ្ឍនិងការសាងសង់លើគ្រប់វិស័យ។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

ប្រភេទដីកម្រិតការសាងសង់ សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដីនិងផ្ទៃក្រឡាដីឡូត៍គិតជាភាគរយ។

សន្ទស្សន៍ប្រើប្រាស់ដី សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការនិងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។

តំបន់ស្នូលនៃការអភិវឌ្ឍ សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់ ឬតំបន់ដែលមានការអភិវឌ្ឍខ្ពស់សម្រាប់គាំទ្រដល់តំបន់ដែលមានសក្តានុពលទាប។

អ័ក្សនៃការអភិវឌ្ឍ សំដៅដល់បណ្តាញផ្លូវគមនាគមន៍ ឬច្រករបៀងតភ្ជាប់ពីតំបន់អភិវឌ្ឍន៍មួយទៅតំបន់អភិវឌ្ឍន៍មួយទៀតដែលអាចឱ្យតំបន់ជាប់ជិតខាងតាមអ័ក្សទាញយកប្រយោជន៍ពីការអភិវឌ្ឍតាមអ័ក្សនេះបាន។

តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលម្ហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់សម្រាប់បម្រើដល់សាធារណជន។

បណ្តាញបៃតង សំដៅដល់សួនសាធារណៈនិងដើមឈើដែលរៀបចំប្រទាក់ក្រឡាគ្នាតាមចិញ្ចើមផ្លូវភ្ជាប់ទៅសួនទីក្រុង។

ការត្រួតពិនិត្យការអភិវឌ្ឍ សំដៅដល់ការត្រួតពិនិត្យការអនុវត្តស្របតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដីនិងស្របតាមបទប្បញ្ញត្តិជាធរមាន។

អាងទន្លេ សំដៅដល់តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់បញ្ចូលទាំងទឹកលើដីនិងទឹកក្រោមដី។

ទឹកក្រោមដី សំដៅដល់ទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំនិងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។

សមុទ្រ សំដៅដល់ប្រភពធនធានទឹកប្រៃនិងជាកន្លែងទទួលរំហូរទឹកមកពីទន្លេ ស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្ទៃកខាងលើ។

ទន្លេ សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្ទៃកខាងលើ ហើយហូរចាក់ទៅសមុទ្រ។

ស្ទឹង សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្ទៃកខាងលើ ហើយហូរចាក់ទៅបឹង ទន្លេ និងសមុទ្រ។

ព្រែក សំដៅដល់ផ្លូវទឹកធម្មជាតិ ឬសិប្បនិម្មិតដែលនាំទឹកចេញ ឬចូលពីទន្លេ ឬស្ទឹង និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្ទៃកខាងលើ។

អូរ សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីជ្រោះនិងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្ទៃកខាងលើ ហើយហូរចូលព្រែក ស្ទឹង ទន្លេ ឬបឹង។

ជ្រោះ សំដៅដល់ជ្រលង ឬល្បាក់ទឹកធម្មជាតិដែលកើតឡើងដោយសារបាតុភូតធម្មជាតិនៃការហូរច្រោះដោយសារចរន្តទឹកពីតំបន់ភ្នំ ឬតំបន់ខ្ពង់រាប។

បឹងបួ សំដៅដល់ល្ហាលទឹកធំល្វឹងល្វើយកើតពីទីជម្រាល ឬជម្រៅធម្មជាតិដែលអាចមានទឹក ឬគ្មានទឹកទៅតាមរដូវកាលនិងមានប្រភពមកពីទន្លេ ស្ទឹង ព្រែក ឬពីតំបន់ផ្ទៃរងទឹកភ្លៀង។

អាងទឹក សំដៅដល់ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិ ឬសិប្បនិម្មិតសម្រាប់ប្រើទៅតាមតម្រូវការ។

ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយបូមលូ ឬទឹកភ្លៀង បណ្តាញលូមេ បណ្តាញលូមេរង ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួមមានតាមលក្ខណៈបច្ចេកវិទ្យា ឬលក្ខណៈធម្មជាតិ។

ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួម សំដៅដល់រោងចក្រសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជន រាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ។

ទឹកកខ្វក់ សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់រួចមានដូចជាទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោមនិងលាមកដែលបញ្ចេញពីលំនៅឋាន បុរីលំនៅឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និងតំបន់រមណីយដ្ឋាន ឬមជ្ឈមណ្ឌលកម្សាន្ត។

សំណល់រាវ សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។

ប្រព័ន្ធលូ សំដៅដល់បណ្តាញប្រមូលនិងបង្ហូរទឹកកខ្វក់រួមមានតំណភ្ជាប់ អណ្តូងលូ និងបណ្តាញលូ(បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង និងបណ្តាញលូខ្នែងរង)។

អាងបង្គន់អនាម័យ  សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យនិងបន្ទប់ទឹកដើម្បីស្តុកនិងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់មុនការហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។

៚៚៙៚៚

**ឯកសារឧបសម្ព័ន្ធ**

- ផែនទីប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ ចក្ខុវិស័យឆ្នាំ ២០៣០
- ផែនទីបណ្តាញផ្លូវស្រុកបរិបូណ៌ ចក្ខុវិស័យឆ្នាំ ២០៣០
- ផែនទីប្រើប្រាស់ដីស្រុកបរិបូណ៌ ឆ្នាំ ២០១៥
- ផែនទីព្រំប្រទល់រដ្ឋបាលស្រុកបរិបូណ៌៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទីប្លង់បណ្តាញផ្លូវ ស្រុកបរិបូណ៌ សម្រាប់ចក្ខុវិស័យ ឆ្នាំ២០៣០















1:40,000



គណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ឆ្នាំង
គណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មស្រុកបរិបូណ៌

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទីប្រើប្រាស់ដីស្រុកបរិបូណ៌ ឆ្នាំ ២០១៥













N
W E
S
1:40,000

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទីប្លង់គោលប្រើប្រាស់ដីស្រុកបរិបូណ៌ ចក្ខុវិស័យឆ្នាំ២០៣០













1:40,000